**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការសើបអង្កេត និង ការសើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **សាន ទិច្ចរ៉ា**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ការស៊ើបអង្កេត និង ការស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **សាន វិច្ឆ័រ៉ា**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សាន វិច្ឆរ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់**ទី នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។**

**សូមលំឱនកាយសម្ដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ**

លោកឪពុក **សាន សំណាង** និងអ្នកម្ដាយ **ជុំ សាឌុន** ដែលលោកអ្នកមានគុណទាំងពីរបានផ្ដល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុង ការរស់នៅប្រចាំថ្ងៃទាំងសម្លៀកបំពាក់ ប្រាក់កាស ចំណីអាហារចំពោះខ្ញុំជាកូន និងបានផ្ដល់នូវការទូន្មានប្រៀនប្រដៅជាមួយនិងដំបូន្មានល្អៗប្រកបដោយព្រហ្មវិហារធម៌តាំងពីកូនតូចរហូតដល់ធំដឹងក្ដី។ លោកទាំងពីរខិតខំព្យាយាមធ្វើការងាររកកំរៃយ៉ាងលំបាក មិនថាឧបសគ្គធំប៉ុណ្ណាក៏លោកទាំងពីរមិនដែលរួញរាឡើយ លោកទាំងពីរតស៊ូជម្នះដើម្បីឲ្យកូនបានល្អ។ បើគ្មានលោកទាំងពីរទេ ខ្ញុំបាទក៏គ្មានថ្ងៃនេះដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះថ្នាក់ដឹកនាំកម្ពុជា ដែលលោកបានដឹកនាំប្រទេសប្រកបដោយសុខសន្តិភាព ហើយព្រមទាំងជួយលើកស្ទួយវិស័យអប់រំឲ្យមានភាពល្អប្រសើរ ប្រសិនបើប្រទេសគ្មានសន្តិភាពខ្ញុំក៏មិនបានសិក្សាមកដល់ថ្ងៃនេះដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ និងលោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ** ទាំងអស់ដែលលោកបានខិតខំបង្ហាត់បង្រៀនដល់ខ្ញុំបាទ ក៏ដូចជានិស្សិតគ្រប់គ្នាអស់ពីកម្លាំងកាយ កម្លាំងចិត្ត ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅដល់រូបខ្ញុំបាទ ឲ្យក្លាយខ្លួនទៅជាពលរដ្ឋល្អនៅក្នុងសង្គមប្រសិនបើគ្មានអ្នកទាំងអស់គ្នាទេខ្ញុំក៏គ្មានថ្ងៃនេះដែរ។

ខ្ញុំសូមគោរព និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោកគ្រូសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលលោកបានលះបង់កំលាំងកាយ កំលាំងចិត្ត ព្រមទាំងពេលវេលា ដ៏មានតម្លៃរបស់លោកជួយបង្ហាត់បង្រៀនផ្ដល់ដំបូន្មានល្អៗដើម្បីឲ្យមានខ្ញុំក្លាយទៅជា និស្សិតល្អ ពលរដ្ឋល្អតាំងពីឆ្នាំទី ២ រហូតដល់ពេលនេះ និងធ្វើការណែនាំសារណាមួយនេះតាំងពីដើមរហូតដល់ចប់។ ខ្ញុំជាកូននិងជាសិស្ស ចងចាំជានិច្ចនៅក្នុងក្រអៅបេះដូងនូវមហាគុណទាំងអស់នេះ ខ្ញុំនឹងតបស្នងសងគុណចំពោះអ្នកមានគុណទាំងពីរ និងសាស្ត្រាចារ្យដោយក្ដីគោរពនិងស្រឡាញ់ជាទីបំផុត។

ជាចុងបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរដល់ លោកអ្នកមានគុណទាំងអស់ សូមឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំបាទជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី ២១ បានឆ្លងកាត់ការសិក្សាផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំមកហើយមិនថាឆ្លងកាត់ឧបសគ្គលំបាកយ៉ាងណាខ្ញុំបាទមិនព្រមបោះបង់ការសិក្សាចោលនោះឡើយព្រោះខ្ញុំបាទយល់ថាការសិក្សាគឺពិតជាសំខាន់ខ្លាំងណាស់ដល់មនុស្សគ្រប់រូបនាពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់ការណាយើងមានចំណេះដឹងគឺយើងអាចធ្វើអ្វីបានដោយងាយស្រួលហើយជាពិសេស យើងអាចស្វែងរកការងារបានសមរម្យ មានជីវភាពធូរធារ អាចជួយក្រុមគ្រួសា រក៏ដូចជាជួយដល់សង្គមជាតិទាំងមូលផងដែរ។ យ៉ាងណាមិញមកដល់ពេលនេះខ្ញុំបានខិតខំអស់ពីកម្លាំងកាយកម្លាំងចិត្តដើម្បីស្វែងរកចំណេះដឹង ហើយខ្ញុំបាទក៏បាន និងកំពុងធ្វើការស្រាវជ្រាវសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅឆ្នាំ ២០២១នេះ។ ខ្ញុំបាទមានមោទនភាពយ៉ាងខ្លាំងបំផុតដែលខ្ញុំអាចមានថ្ងៃនេះដែលទីបំផុតនាងខ្ញុំអាចទទួលបាននូវលទ្ធផលល្អប្រសើរពីការសិក្សា។

ជាមួយគ្នានេះដែរ ក្នុងចំណោមមុខវិជ្ជាជាច្រើនដែលខ្ញុំធ្លាប់បានសិក្សាកន្លងមកមុខវិជ្ជាដែលខ្ញុំយកមកសរសេរនោះគឺទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ។ ខ្ញុំបានជ្រើសរើសយកប្រធានបទមួយគឺ ***"ការស៊ើបអង្កេត និង ការស៊ើបសួរ"*** មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុដែលខ្ញុំបាទសម្រេចជ្រើសរើស យកប្រធានបទមួយនេះមកសិក្សាស្រាវជ្រា វនិងចងក្រងឡើងព្រោះចង់ឲ្យនិស្សិតជំនាន់ក្រោយ បានយល់ច្បាស់អំពីចំណុចមួយចំនួន ដែលមាននៅក្នុងនីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងការស៊ើបសួរ ដើម្បីទុកជាឯកសារមួយសម្រាប់បំពេញនូវតម្រូវការរបស់សិស្សប្អូនជំនាន់ក្រោយដែលមានបំណងចង់ស្រាវជ្រាវបន្ត ទៅលើអ្វីដែលទាក់ទងនឹងប្រធានបទនេះ។ ទន្ទឹមនឹងនេះខ្ញុំជឿជាក់ថានៅក្នុងការសរសេរសារណារបស់ខ្ញុំនេះ គឺច្បាស់ជានៅមានភាពខ្វះចន្លោះជាមិនរួចឡើយទាំងខ្លឹមសារដូចជាកំហុសអក្ខរាវិរុទ្ធ។ ដូច្នេះហើយរាល់កំហុសឆ្គងដែលបានកើតឡើងនេះ ខ្ញុំបាទសូមអភ័យទោសទុកជាមុន ពីសំណាក់គណៈកម្មការសាស្ត្រាចារ្យអស់លោក លោកស្រី និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់។ ខ្ញុំសង្ឃឹមថានឹងទទួលបាននូវការអភ័យទោសពីសំណាក់អ្នកទាំងអស់គ្នា។

ខ្ញុំសូមសូមស្វាគមន៍ទទួលនូវការរិះគន់ ដើម្បីស្ថាបនាពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ អស់លោក លោកស្រី និងមិត្តអ្នកអានគ្រប់ពេលវេលា។

ជាចុងបញ្ចប់ ខ្ញុំសូមគោរពជូនពរដល់លោកគ្រូ អ្នកគ្រូ ដែលជាគណៈកម្មការ លោកគ្រូសាស្ត្រាចារ្យណែនាំអស់លោក លោកស្រី និងមិត្តអ្នកអានទាំងអស់ជួបតែសំណាងល្អទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ចព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


**វាក្យស័ព្ទគតិយុត្តិ** ..................................................................................... iv

**សេចក្តីផ្តើម** ..................................................................................... ១


## ជំពូកទី១

## សមត្ថកិច្ចនៃការបើកការស៊ើបអង្កេត


**ផ្នែកទី១៖ ការស៊ើបអង្កេត** ..................................................................................... ២

**១.១ ការស៊ើបអង្កេតករណីជាក់ស្តែង** ..................................................................................... ២

១.១.១ .និយមន័យនៃបទឧក្រិដ្ឋ និងបទមជ្ឈិមជាក់ស្តែង ..................................................................................... ២

១.១.២ .វិធានការស្រាវជ្រាវ ..................................................................................... ២

១.១.៣ .ការបើកការឆែកឆេរ ..................................................................................... ៣

១.១.៤ .ការឃាត់ខ្លួន ..................................................................................... ៤

១.១.៥ .ការបញ្ជូនខ្លួន ..................................................................................... ៥

**១.២ ការស៊ើបអង្កេតបឋម** ..................................................................................... ៥

១.២.១ វិធានអនុវត្តចំពោះការស៊ើបអង្កេតបឋម ..................................................................................... ៦

១.២.២ ការឆែកឆេរ ..................................................................................... ៦

១.២.៣ ការបញ្ជាឲ្យចូលខ្លួន ..................................................................................... ៧

១.២.៤ ការឃាត់ខ្លួន ..................................................................................... ៧

១.២.៥ មោឃភាព និង មូលវិចារណ៍ ..................................................................................... ៨

**ផ្នែកទី២៖ សមាសភាពមន្ត្រីស៊ើបអង្កេត** ..................................................................................... ៩

**២.១ អង្គការអយ្យការ** ..................................................................................... ៩

២.១.១ តួនាទីអង្គការអយ្យការ ..................................................................................... ៩

២.១.២ ចៅក្រមអយ្យការ ..................................................................................... ៩

២.១.៣ ឋានានុក្រមនៃអង្គការអយ្យការ ..................................................................................... ១០

**២.២ អង្គភាពនគរបាលយុត្តិធម៌** ..................................................................................... ១១

២.១.១ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ..................................................................................... ១១

២.១.២ បេសកម្មនៃនគរបាលយុត្តិធម៌ ..................................................................................... ១២

២.១.៣ មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេស ..................................................................................... ១៣


## ជំពូកទី២

## ការស៊ើបសួរ

**ផ្នែកទី១ អង្គភាពស៊ើបសួរ** ..... ១៧

**១.១ ចៅក្រមស៊ើបសួរ** ..... ១៧

១.១.១ សមត្ថកិច្ចដែនដី ..... ១៧

១.១.២ ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ..... ១៧

១.១.៣ ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក ..... ១៨

១.១.៤ ការស្នើសុំបំពេញកិច្ច ..... ១៨

១.១.៥ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ..... ១៩

**១.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ..... ១៩

១.២.១ ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ..... ២០

**១.៣ ការសួរចម្លើយជនត្រូវចោទ និង ស្តាប់ចម្លើយដើមបណ្តឹង** ..... ២០

១.៣.១ ការពិភាក្សាដេញដោល ..... ២០

១.៣.២ សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ ..... ២១

**១.៤ ការឆែកឆេរនិងចាប់យកវត្ថុតាង** ..... ២២

១.៤.១ វិធានអនុវត្តចំពោះការឆែកឆេរ ..... ២២

១.៤.២ ការធ្វើកោសលវិច័យ ..... ២២

១.៤.៣ ការស្តាប់ទូរស័ព្ទ ..... ២៣

**១.៥ ដីការចាត់អោយស៊ើបសួរជំនួស** ..... ២៤

១.៥.១ ដីការចាត់ឲ្យស៊ើបសួរដែលចេញឲ្យចៅក្រមម្នាក់ទៀត ..... ២៤

១.៥.២ ការអនុវត្តដីការដោយនគរបាលយុត្តិធម៌ ..... ២៤

១.៥.៣ សិទ្ធិអំណាចមន្ត្រីនគបាលយុត្តិធម៌ក្នុងការស៊ើបសួរ ..... ២៥

**១.៦ វិធានការនិរន្តរាយ** ..... ២៦

១.៦.១ ដីការបង្គាប់ឲ្យចូលខ្លួន ..... ២៦

១.៦.២ ដីការបង្គាប់ឲ្យនាំខ្លួន ..... ២៦

១.៦.៣ ដីការបង្គាប់ឲ្យចាប់ខ្លួន ..... ២៧

១.៦.៤ ការឃុំខ្លួនបណ្តោះអាសន្ន ..... ២៨

១.៦.៥ ដីការបង្គាប់ឲ្យឃុំខ្លួន ..... ២៩

**១.៧ ការបិទការស៊ើបសួរ** ..... ២៩

១.៧.១ ដីការដំណោះស្រាយ ..... ២៩

១.៧.២ ការបើកការស៊ើបសួរជាថ្មីលើបន្ទុកថ្មី ..... ៣០

១.៧.៣ ការបញ្ជូនដើម្បីបើកសវនាការជំនុំជំម្រះ ....................................................................................៣១
**ផ្នែកទី២ សភាស៊ើបសួរ** ....................................................................................................៣១
**២.១ បណ្ដឹងឧទ្ធរណ៍ចំពោះដីការរបស់ចៅក្រមស៊ើបសួរ** ....................................................៣១
២.១.១ បណ្ដឹងឧទ្ធរណ៍ចំពោះដីការសម្រេច ដោយអគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញា ឬ ជនត្រូវចោទ ឬ ដើមបណ្ដឹង ........................................................................................................................៣១
២.១.២ ការបន្តការស៊ើបសួរក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ........................................................ ៣៣
២.១.៣ បណ្ដឹងឧទ្ធរណ៍ចំពោះដីការលើកលែងការចោទប្រកាន់ .................................................. ៣៣
**២.២ ការឃុំខ្លួនបណ្ដោះអាសន្ន** ............................................................................ ៣៤
២.២.១ មោឃភាព ............................................................................................................៣៤
២.២.២ អំណាចផ្ទាល់ខ្លួនរបស់ប្រធានសភាស៊ើបសួរ ...........................................................៣៥
**សេចក្ដីសន្និដ្ឋាន** ...........................................................................................................៣៦
**អនុសាសន៍** ...................................................................................................................៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# វាក្យស័ព្ទគតិយុត្ត

-**ការស៊ើបអង្កេត** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអជ្ញា។ ការស៊ើបអង្កេតនេះ ត្រូវបានចែកចេញជាការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម។

-**ការស៊ើបអង្កេតជាក់ស្តែង** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងនៅពេលមានបទល្មើសជាក់ស្តែង បទ) ល្មើសដែលកំពុងប្រព្រឹត្តនិងប្រព្រឹត្តខុសភ្លាម) ។

-**ការស៊ើបអង្កេតបឋម** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង នៅពេលមានបទល្មើសមិនជាក់ស្តែង។

-**ការស៊ើបសួរ** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងដោយចៅក្រមសើបសួរ ដោយមានគោលបំណង ស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកលើជនត្រូវចោទ ដែលមានទិសដៅស្វែងរកការពិតអោយឃើញ ការពិតនៃរឿង។

-**ជនល្មើស** គឺជាជនណាដែលប្រព្រឹត្តអំពើណាមួយល្មើសនឹងច្បាប់។ ជនល្មើស ជាជនដែលប្រព្រឹត្តបទល្មើសជាក់ស្តែង។

-**ជនសង្ស័យ** គឺជាជនដែលត្រូវបានគេសង្ស័យថា បានប្រព្រឹត្តល្មើសដោយផ្ទាល់ ឬបានចូលរួមប្រព្រឹត្តបទល្មើស។ ពាក្យនេះ ត្រូវបានប្រើក្នុងដំណាក់កាលនៃការសើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអជ្ញាខណៈពេល ដែលមិនទាន់មានការចោទប្រកាន់របស់ព្រះរាជអជ្ញា។

-**ជនជាប់ចោទ** គឺជាជនដែលត្រូវបានព្រះរាជអជ្ញា ធ្វើការចោទប្រកាន់ថា បានប្រព្រឹត្តបទល្មើសតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ដើម្បីផ្តល់សិទ្ធិ អំណាចអោយទៅចៅក្រមស៊ើបសួរ បើកការស៊ើបសួរ ដើម្បីស្វែងរកអោយឃើញនូវការពិត។

-**ជនត្រូវចោទ** គឺជាជនដែលត្រូវបានព្រះរាជអជ្ញា ធ្វើការចោទប្រកាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ មានន័យថា ជនដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ពីបទល្មើសណាមួយនៅចំពោះមុខ អង្គជំនុំជម្រះក្នុងពេលបើកសវនាការជំនុំជម្រះ។

-**ពិរុទ្ធជន** គឺជាជនដែលត្រូវបានតុលាការព្រហ្មទណ្ឌ ប្រកាសថាមានទោស តែសាលក្រមដែលតុលាការបានចេញ នោះមិនទាន់ចូលជាស្ថាពរ។

-**ទណ្ឌិត** គឺជាជនដែលត្រូវបានតុលាការព្រហ្មទណ្ឌ ប្រកាសថាមានទោស ហើយសាលក្រមនោះបានចូលជាស្ថាពរ។

# សេចក្តីផ្តើម

ដើម្បីគ្រប់គ្រងប្រទេសជាតិមួយ ឱ្យប្រកបទៅដោយសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព តម្លាភាព និងយុត្តិធម៌ទៅបាន លុះត្រាតែប្រទេសមួយនោះមានវិធានច្បាប់ និងបទដ្ឋានគតិយុត្តនានា ហើយថែមទាំងធានាឱ្យបាននូវប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់នៅក្នុងប្រទេសនោះផងដែរ។ ធានានូវប្រសិទ្ធភាពក្នុងការអនុវត្តនេះ ក៏ទាមទារឱ្យមានការសហការក្នុងការអនុវត្តពីសំណាក់ប្រជាពលរដ្ឋផងដែរ បើមិនដូច្នេះទេ វិធានច្បាប់ និងបទដ្ឋានគតិយុត្តនឹងមិនអាចមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តឡើយ។ ចំពោះជនដែលបានប្រព្រឹត្តប៉ះពាល់ទៅដល់សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព តម្លាភាព និងយុត្តិធម៌សាធារណៈ នោះវិធានច្បាប់ និងបទដ្ឋានគតិយុត្ត និងដាក់ទណ្ឌកម្មចំពោះជននោះ។

ក្រោយពីបានរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ វិធានច្បាប់ និងបទដ្ឋានគតិយុត្តិស្ទើរតែទាំងស្រុងត្រូវបានបំផ្លេចបំផ្លាញ។ ហេតុនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តដោយសម្លេង៨៣/៨៣ នៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០០៧ ហើយត្រូវបានព្រឹទ្ធសភាអនុម័តដោយសម្លេង ៥១/៥១ នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៧ និងត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។ ក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានច្បាប់មួយដែលកំណត់អំពី កិច្ចនីតិវិធីទាំងឡាយក្នុងការបង្ហាញឱ្យច្បាស់នូវនត្ថិភាពនៃបទល្មើស។ ក្រមនីតិវិធីព្រហ្មទណ្ឌតាក់តែងឡើង មានគោលបំណងដើម្បីកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រតិបត្តិតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវនត្ថិភាពនៃបទល្មើសណាមួយ។ ដូចនេះក្រមនីតិវិធីព្រហ្មទណ្ឌ មានភាពចាំបាច់ក្នុងការស្វែងយល់ឱ្យមានភាពច្បាស់លាស់ នូវដំណាក់កាលនីមួយៗនៃក្រមនេះ។ តួយ៉ាង នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមាន ៤ដំណាក់កាលគឺៈ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលចោទប្រកាន់។ ចំពោះ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់តំណាងអយ្យការ គឺស្ថិតក្នុងដំណាក់កាលចោទប្រកាន់ ដែលជាដំណាក់កាលមួយយ៉ាងសំខាន់ ក្នុងចំណោះដំណាក់កាលផ្សេងទៀត។ ហើយដំណាក់កាលនេះ សំដៅលើការចោទប្រកាន់របស់តំណាងអយ្យការ ទៅលើអំពើល្មើសណាមួយ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន។

# ជំពូកទី១
# សមត្ថកិច្ចនៃការបើកការស៊ើបអង្កេត

## ផ្នែកទី១ ការស៊ើបអង្កេត

ការស៊ើបអង្កេត គឺជាការស្រាវជ្រាវប្រមូលភស្តុតាងដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា ។ការស៊ើបអង្កេតនេះផងដែរ ត្រូវបានចែកចេញជាការស៊ើបអង្កេតក្នុងករណីជាក់ស្តែង និងការស៊ើបអង្កេតបឋម ឬហៅថាការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង។

### ១.១ ការស៊ើបអង្កេតក្នុងករណីជាក់ស្តែង

ក្នុងករណីមានបទល្មើសជាក់ស្តែងមួយបានកើតឡើង អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែងក្នុងករណីមាន បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។

#### ១.១.១ និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិម ជាក់ស្តែង

- បទល្មើសដែលកំពុងប្រព្រឹត្ត

- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម

ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក

- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រកីង

- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬ មានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស ។[1]

ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមចាក់ស្តែងផងដែរ បើទោះបីនៅជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលមានអ្នកកាន់កាប់នៅទីនោះសុំឲព្រះរាជអាជ្ញាឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីគ្មានមន្ត្រីនគរបាលយិត្តិធម៌នៅទីនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។[2]

#### ១.១.២ វិធានការស្រាវជ្រាវ ក្នុងករណីជាក់ស្តែង

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៦

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៨

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។[3] វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ ចុះទៅកាន់កន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យលើបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយភស្តុតាងទាំងឡាយណាដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំឲ្យទៅទីកន្លែងណាឆ្ងាយពីកន្លែងប្រព្រឹត្តបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។[4]

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលលើដែនដីជាតិ ដោយគោរពតាមលក្ខណទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨។[5]

**១.១.៣ ការបើកការឆែកឆេរ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ។ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើចំពោះមុខសាក្សីពីរនាក់។សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។សាក្សីមិនអាចជានគរបាល ឬជាកងឬរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ ) ព្រឹក និងក្រោយម៉ោង ១៨ (ប្រាំមួយ)ដប់ប្រាំបីល្ងាចឡើយ លើកលែងតែ (៖

-ក្នុងករណីដែលមានចែងក្នុងមាត្រា ៨៨

-ក្នុងករណីមានសម្រែកស្រែកឲគេជួយពីខាងក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណៈជន

-ក្នុងករណីឆែកឆេរទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ៖

-ការអនុញ្ញាតដោយព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។[6]

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៧

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៩

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៦

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩១

មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរក្នុងការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរក្នុងអគារសារព័ត៌មានសហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ដែលធានាថាប់រងក្នុងការឆែកឆេរនេះប៉ះពាល់ការប្រកបដោយសេរីនូវមុខរបស់អ្នកសារព័ត៌មាននិងធ្វើឲយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។

**១.១.៤ ការឃាត់ខ្លួន**

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនកថាខណ្ឌខាងក្រោមនេះត្រូវបានបំពេញ:

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើឃាត់ខ្លួនពីព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននេះ។ការឃាត់ខ្លួននេះមានថិរវេលា៤៨(សែសិបប្រាំបី)ម៉ោង។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។[7]

ចំពោះបទឧក្រិដ្ឋ ការណាមានតម្រុយដែលបង្ហាយឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបាមល្អ។ ការពន្យារពេលនេះក្នុងសំណុំរឿងទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព។ការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួន ដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យាគឺជាវិធានការពិសេស។ ការពន្យានេះគឺមិនអាចឲ្យលើសពី ២៤ ម៉ោងឡើយ ដោយមិនគិត (ម្ភៃបួន) ពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។

ការពន្យាមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនិតិជន។

- ចំពោះបទឧក្រិដ្ឋ អនិតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។

---

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩៦

- ចំពោះបទមជ្ឈឹម អនិតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។

- ចំពោះបទឧក្រិដ្ឋ អនិតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ។

- ចំពោះបទមជ្ឈឹម អនិតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៨ ម៉ោងឡើយ។

- អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។

ក្នុងរយៈពេលកន្លងផុត ២៤ តាំងពីពេលចាប់ផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទានជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើសបាន ៣០នាទីដោយធានានៃការសម្ងាត់ក្នុងការសន្ទាននោះ ។[8]

**១.១.៥ ការបញ្ជូនខ្លួន**

ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ

- បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ

- ដោះលែងឲ្យមានសេរីភាពឡើងវិញដោយតាមសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ជាអ្នកធ្វើឡើង។[9]

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជ្ញានោះ បុគ្គលនោះត្រូវបានគេនាំខ្លួនភ្លាមទៅព្រះរាជអាជ្ញា ហើយត្រូវបង្ហាញខ្លួននៅចំពោះព្រះរាជាអាជ្ញា។ ប្រសិនបើមានការលំបាកនៃការដឹកបញ្ជូន ឬ ចម្ងាយផ្លូវនោះ រយៈពេលបន្ថែមអាចផ្តល់ឲ្យដោយព្រះរាជអាជ្ញា។ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។[10]

**១.២ ការស៊ើបអង្កេតបឋម**

ការស៊ើបអង្កេតបឋម គឺជាការបើកការស្រាវជ្រាវដើម្បីប្រមូលភស្តុតាងក្នុងករណីបទល្មើសមិនជាក់ស្តែង។ វិធានការក្នុងការស៊ើបអង្កេតបឋម មានការឆែកឆេរ និង ការឃាត់ខ្លួន និង ការបញ្ជូនខ្លួន។

**១.២.១ វិធានការអនុវត្តចំពោះការស៊ើបអង្កេតបឋម**

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩៨

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៣

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៤

វិធានការអនុវត្តចំពោះការស៊ើបអង្កេតបឋមនេះ គឺមិនខុសគ្នាអ្វីជាមួយនឹងការស៊ើបអង្កេតក្នុងករណីជាក់ស្តែងនោះទេ ដែលមានដូចជាកំណត់ហេតុលើការការស្រាវជ្រាវ និងការពិនិត្យការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ និងការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា។[11]

**១.២.២ ការឆែកឆេរ**

កាលណាបើកការស៊ើបអង្កេតជាបឋមនោះទាក់ទងនឹងបទឧក្រិដ្ឋ និង បទមជ្ឈិម មន្ត្រីនគបាលយុត្តិធម៍អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។ មន្ត្រីនគបាលយុត្តិធម៍ ជាបឋមត្រូវទទួលបានការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។

ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ នោះត្រូវសរសេឲ្យបានច្បាស់លាស់ ក្នុងកំណត់ហេតុថាអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬ បដិសេធការឆែកឆេរប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីការអនុញ្ញាត្តឲ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី២ នាក់។ សាក្សី ត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។[12]

សាក្សីមិនអាចជានគបាលឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ការឆែកឆេរ មិនអាចផ្តើមមុនម៉ោង៦ពេល និង ក្រោយម៉ោង ១៨ ល្ងាចឡើយ។ ចំពោះការឆែកឆែរនៅអាគារសារព័ត៍មាន មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអាគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មាន សរសេរ ឬ សហគ្រាសនៃសារព័ត៌មានសោតទស្សន៍បាន តែចំពោះមុខព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ម្នាក់ ដែលធានាការ៉ាប់រងកុំឲ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌ មាន និងធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ និងការបិទស្លាកបោះត្រាលើវត្ថុតាង យោងតាមមាត្រា ៩១ និង ៩២ ដែលមានចុះនៅក្នុងនោះមាន៖ [13]

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៥

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១១៣

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩១

• អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ របស់សាក្សីនីមួយៗ

• មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង និងត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ

• ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែល ចាប់។

• កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទី កន្លែង ឬដោយសាក្សីពីរនាក់។[14]

### ១.២.៣ ការបញ្ជាឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម

មន្ត្រីនគបាលយុត្តធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ។

បុគ្គលដែលកោះហៅត្រូវចូលបង្ហាញខ្លួន។ក្នុងករណីរឹងទទឹម មន្ត្រីនគបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឲ្យចូលខ្លួន។ បញ្ជាឲ្យចូលខ្លួននេះ ត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ពន្ធ័ កាលបរិច្ឆេទ និង ចុះហត្ថលេខាដោយព្រះរាជអាជ្ញា និង មានបោះត្រា។[15]

បញ្ជាឲ្យចូលខ្លួន អនុញ្ញាតឲ្យនគបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួន។

### ១.២.៤ ការឃាត់ខ្លួន

ការឃាត់ខ្លួនជនជាប់សង្ស័យ អាចធ្វើបានកាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ បទមជ្ឈិម។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនកថាខណ្ឌខាងក្រោមនេះត្រូវបានបំពេញ:

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើឃាត់ខ្លួនពីព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននេះ។ កាតឃាត់ខ្លួននេះមានចិរវេលា ៤៨ម៉ោង។ ចិរវេលាត្រូវចាប់គិ (សែសិបប្រាំបី)តពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩២

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៤

ចំពោះបទឧក្រិដ្ឋ ការណាមានតម្រុយដែលបង្ហាយឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹតទៅបាមល្អ។ ការពន្យារពេលនេះត្រូវសំណុំរឿងទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព។ ការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងរឿង។ ការពន្យាគឺជាវិធានការពិសេស។ ការពន្យានេះគឺមិនអាចឲ្យលើសពី ២៤ ម៉ោងឡើ (ម្ភៃបួន)យ ដោយមិនគិតពីចិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។

- ការពន្យាមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនិតិជន។

- ចំពោះបទឧក្រិដ្ឋ អនិតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។

- ចំពោះបទមជ្ឈឹម អនិតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។

- ចំពោះបទឧក្រិដ្ឋ អនិតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ។

- ចំពោះបទមជ្ឈិម អនិតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៨ ម៉ោងឡើយ។

- អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពំអាចត្រូវគេឃាត់ខ្លួនបានឡើយ។[16]

### ១.២.៥ មោឃភាព និង មូលវិចារណ៍

គ្រប់កិច្ចនៃការអនុវត្តដែលច្បាប់បានកំណត់រួចហើយប្រសិនបើមានការអនុវត្តខុសកិច្ចនីតិវីធីណាមួយ នោះកិច្ច ឬ ផលដែលបានការស៊ើបអង្កេតត្រូវចាត់ទុកជាមោឃភាព ។[17] ជាកិច្ចចុងក្រោយនៃការស៊ើបអង្កេតត្រូវមានមូលវិចារណ៍ ដែលច្បាប់បានកំណត់ថាជាអំណាចធ្វើមូលវិចារណ៍របស់ចៅក្រម ។ជាគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៍មានប៉ុណ្ណោះ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគបាលយុត្តិធម៌ត្រូវទុកជា បន្ទាល់( ឯកសារដើម) មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបាន

---

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩៦

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៩

ដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។ ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដដែលធ្វើដោយមន្ត្រីនគបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម។[18]

## ផ្នែកទី២ សមាសភាពមន្ត្រីស៊ើបអង្កេត

### ១.១ អង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នមួយដែលអមជាមួយសាលាជំម្រះក្តីគ្រប់ជាន់ថ្នាក់ ហើយក្នុងនោះដែលមានតួនាទីរបស់ ចៅក្រមអង្គការអយ្យការដែលអនុវត្តក្នុងមុខងារ និងការគោរពនាយឋានានុក្រមអង្គការអយ្យការ នោះហៅថា ព្រះរាជអាជ្ញា។

#### ១.១.១ តួនាទីអង្គការអយ្យការ

តួនាទីអង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសនិដ្ឋានឲតុលាការអនុវត្តច្បាប់។ អង្គអយ្យការធានារ៉ាប់រងសេចក្តីសម្រេចខាងបទប្រហ្មទណ្ឌ ព្រមទាំងធានារយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីការឲចាប់ខ្លួន។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ការចោទប្រកាន់គឺ ជាតួនាទីរបស់អង្គការអយ្យការដោយធ្វើឡើងតាមរយៈបណ្តឹងអាជ្ញាមាត្រា១៣១ [19]ថ្មីរដ្ឋធម្មនុញ្ញចែងថាមានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលបើកសវនាការក្នុងរឿងក្តីព្រហ្មទណ្ឌ។[20]

#### ១.១.២ ចៅក្រមអយ្យការ

ចៅក្រមអយ្យការ គឺជាចៅក្រមក្នុងចោទប្រកាន់ នោះហៅថាព្រះរាជអាជ្ញា ហើយរួមមាន:

១ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារងនិងព្រះរាជអាជ្ញាអមតុលាការកំពូល។អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានតួនាទី និង សិទ្ធិអំណាចដូចជា តំណាងអោយអង្គការអយ្យការក្នុងតុលាការកំពូល និងពិនិត្យលើបណ្តឹងសារទុក្ខ និង បណ្តឹងសើរើ រួមទាំងបណ្តឹងតវ៉ាផ្សេងៗ។[21]

២ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានតួនាទី និង សិទ្ធិអំណាចច្រើន ដូចជា តំណាងអង្គការអយ្យការសាលាឧទ្ធរណ៍ និងឃ្លាំងមើលការអនុ

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១១០

[19] រដ្ឋធម្មនុញ្ញ មាត្រា ១៣១ថ្មី

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣១ និងមាត្រា ៣២

វត្តច្បាប់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង ធ្វើអធិការកិច្ច និង ឃ្លាំងមើលត្រួតពិនិត្យអង្គភាពនគបាលយុត្តិធម៌ និង ការងារផ្សេងៗ។[22]

៣ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។មានតួនាទីនិង សិទ្ធិអំណាច ដូចជាដឹកនាំសម្រប សម្រួលសកម្មភាពរបស់មន្ត្រី ឬ ភ្នាក់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចុះទៅកាន់និងដឹកនាំកន្លែងស៊ើបអង្កេតផ្ទាល់ ដក សិទ្ធិមន្ត្រីស៊ើបអង្កេត ឬដាក់ជំនួសមន្ត្រីស៊ើបអង្កេត និង ធ្វើអធិការកិច្ចនគបាលយុត្តិធម៌ និង ត្រួតពិនិត្យវិធានការនៃ ការឃាត់ខ្លួន និង ទម្រង់ការផ្សេងៗ។[23]

**១.១.៣ ឋានានុក្រមនៃអង្គការអយ្យការ**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលា ដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាលាយលក្ខណ៍ជាអក្សរដែលត្រូវដាក់ចូលក្នុងសំណុំរឿងឲអគ្គ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើ កាចោទប្រកាន់តាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឲធ្វើការតម្កល់ទុកមិនចាត់ការនូវរឿងក្តីព្រហ្ម ទណ្ឌមួយបានឡើយ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតក្នុងសមត្ថកិច្ចរស់ ខ្លួន។អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឲចោទប្រកាន់ឬ ចាត់ឲចោទប្រកាន់ឬធ្វើសេចក្តីសនិដ្ឋានយ៉ាងណាដែលខ្លួន យល់ថាជាការគួរ។

ព្រះរាជអាជ្ញាមានអំណាចលើចៅក្រមអយ្យការដែលស្ថិតក្នុងដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិប ញ្ញាឲចោទប្រកាន់ ឬចាត់ឲចោទប្រកាន់ ឬធ្វើសេចក្តីសនិដ្ឋានយ៉ាងណាដែលខ្លួនយល់ថាជាការគួរ។[24] ចៅក្រម អយ្យការគ្រប់រូប ត្រូវគោរពតាមធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រមដែលរួមមាន ៖

រដ្ឋមន្ត្រីក្រសួ-ងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យកា រហើយអាចធ្វើអធិបញ្ញាតាមការណែនាំជា លាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួង យុត្តិធម៌ជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល-

---

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៤

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៩

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលត្រូវធ្វើការក្រោមការដឹកនាំ និងការ-ទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

អគ្គព្រះរាជអាជ្-ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍

-ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។

ព្រះរាជអាជ្ញាអមសាលាដំបូង- គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញាទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំនិងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន ។[25](មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ជាគោលការណ៍ព្រះរាជអាជ្ញាមានសេរីភាពពេញលេញក្នុងការសម្រេចពីការចោទប្រកាន់។ ប៉ុន្តែដោយហេតុថាព្រះរាជអាជ្ញាស្ថិតនៅក្នុងអង្គ ដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញា ត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើតាមឋានានុក្រមរបស់ខ្លួន ដែលបង្គាប់បញ្ជាឲ្យធ្វើការចោទប្រកាន់ លើអំពើអ្វីមួយ ទោះបីជាព្រះរាជអាជ្ញាខ្លួនឯងយល់ឃើញថាពុំគួរចោទប្រកាន់ក៏ដោយ។ ប៉ុន្តែនៅពេលសវនាការចៅក្រមអយ្យការ ធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីភាពតាមការដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជ្ជៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[26](មាត្រា៣០ ក្រមនីតិវិធីព្រហ្មទណ្ឌ)

### ១.២ អង្គភាពនគបាលយុត្តធម៍

អង្គភាពនគបាលយុត្តិធម៍ គឺជាមន្រ្តីនគបាលដែលជួយសម្រួលសរាល់កិច្ចក្នុងរឿងព្រហ្មទណ្ឌ និង អនុវត្តតាមដីការរបស់ព្រះរាជអាជ្ញា និងតុលាការ ។

#### ១.២.១ សមត្ថកិច្ចដែនដីរបស់មន្រ្តីនគបាលយុត្តិធម៍

មន្រ្តីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចក្នុងរង្វង់ដែនដីសមត្ថកិច្ចរបស់ខ្លួនដែលត្រូវបានចាត់តាំង។ នៅរាជធានីភ្នំពេញ មន្រ្តីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ។ [27]

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣០

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦៧

**ការពន្លាតសមត្ថកិច្ចដែនដី៖ ករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង** សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌អាចពង្រីកលើវិសាលភាពនៃដែនដីប្រទេសទាំងមូល ដោយមានការអនុញ្ញាតពីព្រះរាជអាជ្ញា អាចធ្វើដោយផ្ទាល់) មាត់ ប៉ុន្តែត្រូវចុះនិទ្ទេសក្នុងលិខិតស៊ើបអង្កេត។ កាលណាធ្វើប្រតិបត្តិការនៅក្រោមមណ្ឌលរបស់ខ្លួននោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ក្នុងក្របខណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់អោយស៊ើបសួរជំនួសក្នុងករណីបន្ទាន់ ចៅក្រមនេះអាចអនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការ នៅលើវិសាលភាពដែនដីជាតិទាំងមូល និងត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។ [28]

វិធាននៃសមត្ថកិច្ចខាងដែនដីដែលបានបញ្ញត្តនៅក្នុងមាត្រាមុនៗនេះ មានលក្ខណៈដាច់ខាត។ បើមិនគោរពតាមនោះទេ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ។[29] មណ្ឌលរដ្ឋបាលក្នុងការបំពេញការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲបម្រើការងារ។

នៅភ្នំពេញមន្ត្រីនគបាលយុត្តិធម៌មានវិសាលភាពនៃក្រុងទាំមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ ទៅកន្លែងណាក៏ដោយ។ សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាលដែលមន្ត្រីនោះចាត់តាំងឲទៅបម្រើការងារ។សេចក្តីសម្រេចនោះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

### ១.២.២ បេសកកម្មរបស់នគរបាលយុត្តិធម៌

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌មានច្រើន ក្នុងនោះមន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីទទួលពាក្យបណ្តឹងទាមទារ ព្រមទាំងទទួលបណ្តឹងបរិហារផ្សេងៗដែលជនរង គ្រោះឬដើមបណ្តឹងបានដាក់ពាក្យបណ្តឹងមកអង្គភាពរបស់ខ្លួន ព្រមទាំងធ្វើកំណត់ហេតុពីសេចក្តីរាយការណ៍របស់អ្នកប្តឹងផងដែរ ទន្ទឹមនឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ ពិនិត្យបទល្មើសទាំងឡាយដែលកើតមានឡើង។[30]

កាលណាទទួលបានពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចាប់ផ្តើមភ្លាមៗ ដោយធ្វើការស៊ើបអង្កេត ឬបញ្ជូនកំណត់ហេតុស្តីពី ការដាក់ពាក្យប្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការបន្តទៀត។ គ្រប់បណ្តឹងដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលនោះ តម្រូវឱ្យមានជាកំណត់ហេតុ។ កំណត់ហេតុនោះត្រូវស្រង់ដោយត្រឹមត្រូវ ពីសេចក្តីរាយការណ៍របស់អ្នកប្តឹង។ ដោយឡែក ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាច ហៅអ្នកបកប្រែភាសា

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦៨

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦៩

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៦

ម្នាក់ ដែលត្រូវស្បថតាមជំនឿ ឬសាសនាថា (ប្រសិនបើភាគីណាមួយគឺជាជនបរទេស)ខ្លួននឹងបកប្រែភាសា ឱ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍។ អ្នកបកប្រែភាសា មិនអាចត្រូវបានជ្រើសរើស ក្នុងចំណោមនគរបាលឬ កងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការបំពេញនូវការងារ ជាមួយខ្លួនបានឡើយ។

កំណត់ហេតុ នៃការដាក់ពាក្យបណ្តឹងមានចុះសេចក្តីដូចតទៅ៖

- ឈ្មោះនិងឋានៈ របស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ
- កាលបរិច្ឆេទ ។[31]

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខា ដោយមន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង។ រាល់ការឆូត ការថែម និងការយោងត្រូវតែបញ្ជាក់ដោយចុះហត្ថលេខារបស់ មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង នៅរឹមទំព័រ។ បន្ទាប់មក មុននឹងចុះហត្ថលេខាឬផ្តិតមេដៃ អ្នកប្តឹងត្រូវអាន នូវកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានកំណត់ហេតុដោយសំឡេងខ្លាំងៗ ដើម្បីឱ្យអ្នកស្តាប់បានលឺច្បាស់។ សូមបញ្ជាក់ថា នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីបណ្តឹងមួយ នៅគ្រប់ពេល មានការដាក់ពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនៅក្នុងបញ្ជីនូវនិទ្ទេសដែលមានសេចក្តីដូចតទៅ៖

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិសច្ឆេទនៃការដាក់ពាក្យប្តឹង
- ឈ្មោះ ឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុ ស្តីពីការដាក់ពាក្យប្តឹង។
- ប្រភេទនៃអំពើដែលប្តឹង
- ចំណាត់ការលើបណ្តឹង មានដូចជា បញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេត។ បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍ សម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ។

នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់តុលាការ។ ហើយនគរបាលយុត្តិធម៌មានភារកិច្ចត្រួតពិនិត្យទៅលើបទឧក្រិដ្ឋ មជ្ឈិម និងលហុ និង កំណត់អត្តសញ្ញាណបុគ្គល និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង សួរចម្លើយ និង អនុវត្តនីតិវិធីជាច្រើនផ្សេងៗ ដែលច្បាប់អនុញ្ញាត។[32]

### ១.២.៣ ឋានន្តរស័ក្តិនិងមុខងារ និង ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈផ្សេងទៀត

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៧២

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៧៣

មន្ត្រីនគរបាលយុត្តិធម៌ដែលមានឋានន្តរសក្តិ និងមុកងារដូចមានចែងក្នុងមាត្រា៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌ នឹងមានលក្ខណៈសម្បត្តិក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ដោយស្វ័យប្រវត្តិ។ គុណសម្បត្តិទាំងនោះមានដូចជា៖

❖ មន្ត្រីនគរបានជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីត្រីឡើងទៅ ដែលបានបំរើការងារយ៉ាងតិចបំផុត២ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

❖ នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំរើការងារយ៉ាងតិចបំផុត២(ពីរ)ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួច ហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

❖ អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម៖

+ អភិបាល និងអភិបាលរង ខេត្ត ក្រុង អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

+ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាន នាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

+ ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

+ ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក នៃ

->នាយកដ្ឋាននគរបាលព្រំដែន «ចំពោះបទល្មើសឆ្លងដែន»

-> មន្ទីរប្រឆាំងគ្រឿងញៀន

-> នាយកដ្ឋាននគរបាលទេសចរណ៍

-> ស្នងការពិសេសការពារបេតិភ័ណ្ឌ។

+ ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

+ ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌ ចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា៖

>- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយល័យព្រហ្មទណ្ឌកំរិតស្រាល

-> ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

-> ការិយាល័យនគរបាលសេដ្ឋកិច្ច

-> ការយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-> ការិយាល័យប្រឆាំងគ្រឿងញៀន

-> ការិយាល័យប្រឆាំងភេរវកម្ម និង

-> ការិយាល័យជនបរទេស ។

+ អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ ។

+ ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ «ចំពោះបទល្មើសចរាចរ»។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ «ចំពោះបទល្មើសអាវុធ ជាតិផ្ទុះ» ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន អនុប្រធាន ផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ ។

+ ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ «ចំពោះបទល្មើសព្រហ្មទណ្ឌ» ។

+ មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

+ មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រឆាំងខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

+ មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

+ ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

+ ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់ ។

រដ្ឋមន្ត្រី ជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣ នៃមាត្រានេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។[33]

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲពិនិត្យបទល្មើស ត្រូវស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា ក្នុងពេលបំពេញមុខអារនេះ។ បែបបទ និងនីតិវិធីការផ្តល់នីតិសម្បទា ត្រូវប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦០

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈត្រូវស្បថថា បំពេញមុខងារដោយស្មោះត្រង់។សម្បថត្រូវធ្វើនៅសាលាដំបូង។ ពាក្យសម្បថត្រូវប្រកាសដោយក្រសួងយុត្តិធ៌។

រាល់កំហុសទាំងឡាយ ប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវឲដំណឹងដល់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាប្រកាសរដ្ឋមន្ត្រីដែលមន្ត្រីឬភ្នាក់ងារនៅក្រោម ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ពីចំណាត់ការអំពីវិន័យ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត។[34]

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨២

# ជំពូកទី២
# ចៅក្រមស៊ើបសួរ

## ផ្នែកទី១ អង្គភាពស៊ើបសួរ

ការស៊ើបសួររបស់អង្គភាពស៊ើបសួរដែលត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ ឬបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមសមត្ថកិច្ចដែនដី។

### ១.១ ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ ជាជាចៅក្រមដែលមានសមត្ថកិច្ចក្នុងការស៊ើបសួរស្វែងរកការពិត នៅពេលមានការចោទប្រកាន់ពីព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវតែជាការសម្ងាត់ ហើយការស៊ើបសួរអាចត្រូវបើកបានចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម។[35] ចំពោះបទឧក្រិដ្ឋត្រូវតែបើកការស៊ើបសួរមិនអាចខានបានចំណែកឯបទមជ្ឈិម អាចបើកការស៊ើបសួរក៏បាន មិនបើកការស៊ើបសួរក៏បាន។ [36]

### ១.១.១ សមត្ថកិច្ចដែនដី

ចៅក្រមដែលមានសមត្ថកិច្ចនោះគឺ ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស ឬ ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ឬ ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ ករណីមានវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល។ ការសម្រេចនេះបិទការតវ៉ា។ [37]

### ១.១.២ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬអញ្ញាតជន។

---

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២១

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២២

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៣

ចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹង ដោយមានការតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែអនុវត្តអោយបានម៉ឺងម៉ាត់ និង តាមនីតិវិធីក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានឡើយ។[38]

### ១.១.៣ កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ក្នុងការដាក់បន្ទុក និង ដោះបន្ទុក

ចៅក្រមស៊ើបសួរ នៅពេលទទួលបានដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាមក ចៅក្រមស៊ើបសួរចាប់ផ្ដើមដំណើរការនីតិវិធីនៃការស៊ើបសួរ។ ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរ មានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និង ដោះបន្ទុក។[39]

### ១.១.៤ ការស្នើសុំបំពេញកិច្ច

ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ករណី ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីការបដិសេធក្នុងរយៈពេល ១៥ ថ្ងៃ។ ដីការនេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹង ដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[40]

ការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរចម្លើយខ្លួន ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬ សាក្សី សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខអក្សរ និង ត្រូវមានសំអាងហេតុ។ ចៅក្រមស៊ើបសួរអាចបដិសេធបានក្នុងថេរវេលា ១ ខែក្រោយពេលទទួលបានពាក្យសុំ។ [41]

ការស្នើសុំបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរចម្លើយខ្លួន ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬ សាក្សី សួរតទល់គ្នា ឬ ចុះទៅ

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៤

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៧

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣២

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៣

ដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខអក្សរ និង ត្រូវមានសំអាងហេតុ។ ចៅក្រមស៊ើបសួរអាចបដិសេធបានក្នុងថេរវេលា ១ ខែក្រោយពេលទទួលបានពាក្យសុំ។[42]

ការស្នើសុំបំពេញកិច្ចទៅចៅក្រមស៊ើបសួរក្នុងពេលស៊ើបសួរនោះ គឺគ្រាន់តែជាការស្នើសុំប៉ុណ្ណោះ ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការបដិសេធនៃការស្នើសុំបំពេញកិច្ចនោះ។

### ១.១.៥ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

កាលណាការស៊ើបសួរត្រូវបានបើកបុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើង។កាលណាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមលិខិត លិខិតនេះត្រូវដាក់បញ្ចូនក្នុងសំណុំរឿង។ កាលណាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ។[43] ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដល់ព្រះរាជអាជ្ញា និង ដល់ជនត្រូវចោទ។

ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា ចៅក្រមស៊ើបសួរបញ្ជូនពាក្យបណ្តឹងនេះទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាអាចត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយម្យ៉ាង ដីការសន្និដ្ឋានបញ្ជីនរឿងឲ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ។[44] ព្រះរាជអាជ្ញា អាចសុំទៅចៅក្រមស៊ើបសួរ កុំឲ្យបើកការស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេច ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីការសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតម្កល់ទុកនូវប្រាក់មួយចំនួនតាមច្បាប់កំណត់។[45]

## ១.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ គឺជាវិធានការក្នុងការស្រាវជ្រាវ ឬស៊ើបសួរក្នុងគោលបំណងស្វែងរកការពិតនៃសំណុំរឿងដែលព្រះរាជអាជ្ញាបានប្តឹងមក តាមរយៈដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៤

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៧

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៩

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤០

ដើម្បីផ្តល់ភាពងាយស្រួលដល់ការស្រាវជ្រាវនោះត្រូវដាក់ជនមួយចំនួនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ និង សួរចម្លើយ រួមទាំងការស្តាប់ចំម្លើយ ជនត្រូវចោទ និងដើមបណ្តឹង និងសាក្សីផងដែរ។

### ១.២.១ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ

ការជូនដំណឹងអំពីការដាក់ឲស្ថិតនៅក្រោមការពិនិត្យ នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននោះឲ្យបានដឹងរឿងដែលត្រូវចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់។ ចៅក្រមសើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមសើបសួរត្រូវទទួលចម្លើយនោះភ្លាម។

ចៅក្រមសើបសួរប្រាប់ជនត្រូវចោទឲបានដឹងអំពីសិទ្ធិក្នុងការជ្រើសរើសមេធាវី ឬក្នុងការចាត់តាំងមេធាវីរបស់ខ្លួន ដោយអនុវត្តតាមលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីសឲអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទបានទទួលដំណឹងថា

- ខ្លួនត្រូវតែជូនព័ត៌មាន ដល់ចៅក្រមសើមសួរ នៅពេលណាដែលខ្លួនផ្លាស់ប្តូរអាស័យដ្ឋាន

- គ្រប់ការឲដំណឹង បានធ្វើឡើងតាមអាស័យដ្ឋានចុងក្រោយ របស់ជនត្រូវចោទនោះត្រូវចាត់ទុកថាបានធ្វើឡើងសាមីខ្លួនផ្ទាល់។

ការឲ្យដណឹងព្រមទាំងការប្រកាសស្តីអំពីអាស័យដ្ឋាននោះ ត្រូវចុះកំណត់ហេតុនៅពេលដែលចូលបង្ហាញខ្លួនលើកដំបូង។[46] ក្នុងករណីជនត្រូវចោទជាជនជាតិបរទេស ចៅក្រមស៊ើបសួរអាចរកជំនួសក្នុងការបកប្រែ។[47]

## ១.៣ ការសួរចម្លើយជនត្រូវចោទ និង ការស្តាប់ចម្លើយដើមបណ្តឹង

ការសួរចម្លើយជនត្រូវចោទ និង ការស្តាប់ចម្លើយដើមបណ្តឹង គឺជាកិច្ចមួយក្នុងចំណោមការស៊ើបសួរស្វែងរកការពិត។ ចៅក្រមស៊ើបសួរអាចសួរ និង ស្តាប់ចំម្លើយគ្រប់បុគ្គលទាំងអស់ដែលមានការពាក់ពន្ធ័ក្នុងសំណុំរឿង។

### ១.៣.១ ការសួរចម្លើយជនត្រូវចោទ

ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបាននៅចំពោះមុខមេធាវីរបស់ជនត្រូវចោទប៉ុណ្ណោះ។ ប្រសិនបើជននោះមានមេធាវីអម។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ ខែ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានការវត្តមានរបស់មេធាវី។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវ ដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាស់នូវវត្តមានមេធាវីខ្លួន។

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៣

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៤

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរកអាចធ្វើកាសួរចម្លើយ មិនបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែដូចបានចែងនៅក្នុងមាត្រា ១៤៤ នៃក្រមនេះ។(ជំនួយរបស់អ្នកបកប្រែ) ក្នុងការសួចម្លើយ ព្រះរាជអាជ្ញា និង មេធាវី អាចសាកសួរបាន ប្រសិនបើមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។[48]

**១.៣.២ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី។ ក្នុងករណីចៅក្រមសស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុតក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត៥ថ្ងៃមុនការស្តាប់ចម្លើយ។ នៅក្នុងចិរវេលានេះ មេធាវីអាចពិនិត្(ប្រាំ)យសំណុំរឿងនីតិវិធីបាន។

ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានស្តាប់ចម្លើយនៅចំពោះមុខមេធាវីរស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួនតាមពេលកំណត់ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវី។ ក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងបោះបង់ចោលនូវវត្តមានរបស់មេធាវីរបស់ខ្លួន។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[49]

ចៅក្រមស៊ើបសួរ អាចរកអ្នកបកប្រែដូចបានចែងនៅមាត្រា ១៤៤ នៃក្រមនេះ។ ក្នុងពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញា និង មេធាវីអាចលើកសំនួរមកសួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។[50]

**១.៣.៣ សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ**

ជនត្រូវចោទមានសិទ្ធិពេញលេញក្នុងការការពារខ្លួនដោយមានមេធាវីអម ទាំងក្នុងការសួរចម្លើយ និង ការស្តាប់ចម្លើយ ឬ កិច្ចពិភាក្សាសួរដេញដោល។ មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួន នៅក្នុងពន្ធនាគារ និងមណ្ឌលឃុំខ្លួន។ ការសន្ទនារវាងមេធាវីនិងជនត្រូវចោទមិនអាច

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៥

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៥០

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៤

ត្រូវគេចតបានទេ។ មេធាវីអាចអានលិខិតឲកូនក្តីរបស់ខ្លួនស្តាប់។ ផ្ទុយទៅវិញមេធាវីមិនអាចឲលិខិតនៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនឡើយ។[51]

## ១.៤ ការឆែកឆេរ និង ការចាប់យកវត្ថុតាង

ក្នុងចំណុចនៃការស៊ើបសួរស្វែងរកការពិត មានការឆែកឆេរ និង ការចាប់យកវត្ថុតាងដើម្បីជាការប្រមូលរកព័ត៌មានក្នុងការស៊ើបសួរ របស់ចៅក្រមស៊ើបសួរ។

### ១.៤.១ វិធានអនុវត្តចំពោះការឆែកឆេរ

ចៅក្រមស៊ើបសួរ អាចធ្វើការឆែកឆេរបាន។ ចៅក្រមស៊ើសសួរ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ ទីកន្លែងទេត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រត្តិបត្តិការក្នុងការឆែកឆេរនោះឡើយ។

ចៅក្រមស៊ើបសួរមិនអាចឆែកឆេរមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេ លើកលែងតែ:

– ករណីឆែកឆេរនៅទីកន្លែងដែលបើកចំហរដល់សាធារណៈជន

– ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី។

ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់។

កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីមួយៗ ។កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមាន របស់ប្រធានគណៈមេធាវី ឬប្រតិភូគណៈមេធាវីនេះ។[52] វត្ថុដែលបានពីការឆែកឆេរ ត្រូវតែបិទស្លាកបោះត្រាលើវត្ថុតាងនោះជាចាំបាច់។[53]

### ១.៤.២ ការធ្វើកោសលវិច័យ

នៅក្នុងករណីមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោលសវិច័យដោយខ្លួនឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។

កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីការដោយមានសំអាងហេតុ។ ដីការសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិន បើពាក្យសុំនោះចេញពីព្រះរាជ

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤៩

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៥៩

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦០

អាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនោះចេញពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ ដីការសម្រេចនេះត្រូវជូនដំណឹងឲ្យដល់អ្នកប្តឹងសុំជាបន្ទាន់។[54]

ការធ្វើកោសលវិច័យ ត្រូវធ្វើដោយអ្នកជំនាញហើយអ្នកជំនាញនោះត្រូវតែជាអ្នកដែលច្បាប់បានអនុញ្ញាត ក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។[55]

### ១.៤.៣ ការស្តាប់ទូរស័ព្ទ

ការស្តាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ តាមតម្រូវការចាំបាច់ដើម្បីសម្តែងឲ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យស្តាប់ និង ថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងក្នាតាម មធ្យោបាយទូរគមនាគមន៍ផងដែរ ដូចជាសារទូរស័ព្ទឬសារតាមអិនធើណែត។

ចៅក្រមស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញ តាំងឧបករណ៍ បច្ចេកទេស និងធ្វើការថត ។ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីការសម្រេចរបស់ខ្លួនអំពីប្រភេទនៃ ទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលបេសកកម្ម។

អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញពាក្យសុំរបស់ចៅក្រមស៊ើបសួរ។ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំង ត្រូវជូនពណ៌ មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹតទៅនៃបេសកកម្មជាអាទិ៍ អំពីការលំបាកជាយថាហេតុ។ កាលំណាបេសកកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះ ត្រូវចម្លង ជាលាយលក្សណ៍អក្សរនូវសម្លេងដែលថតបាន។ ការធ្វើឲ្យទៅជាលាយលក្សណ៍អក្សរនេះ ឆ្លុះបញ្ចាំង យ៉ាងត្រឹមត្រូវនូវខ្លឹមសារនូវសម្លេងដែលថតបាន។ សម្លេងដែលថតបាននេះត្រូវប្រគល់ជូនទៅចៅ ក្រមស៊ើបសួរ និងបិតស្លាក។

គ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះ។ការចូលទៅក្នុងកន្លែងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូល ហេតុអ្វីបានទេ ទោះបីជាកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីការចាត់ឲ្យស៊ើបសួរជំនួសបានដែរ។[56]

## ១.៥ ដីកាចាត់ឲ្យស៊ើបសួរជំនួស

ការជំនួសនៃការស៊ើបសួរ ដោយការចេញដីការចាត់ឲ្យស៊ើបសួរជំនួសចៅក្រមម្នាក់ និង ការចាត់ឲ្យស៊ើបសួរជំនួសដោយដីកាទៅមន្ត្រីនគបាលយុត្តិធម៌ ក្នុងការបំពេញកិច្ចក្នុងចំណុចណាមួយនៃការស៊ើបសួរ។

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦២
[55] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦៣
[56] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧២

### ១.៥.១ ដីកាចាត់ឲ្យស៊ើបសួរដែលចេញឲ្យចៅក្រមម្នាក់ទៀត

ដីការចាត់ឲ្យស៊ើបសួរជំនួស តាមរយៈដីការចាត់ឲ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឲ្យចៅក្រមនៃតុលាការ របស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរនោះ។[57]

កាលណាដីការចាត់ឲ្យស៊ើបសួរជំនួស ត្រូវបានចេញឲ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនេះ ប្រើប្រាស់សិទ្ធិអំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ដែលបានផ្តល់ឲ្យ។[58]

### ១.៥.២ ការអនុវត្តដីការដោយនគបាលយុត្តិធម៌

ដីការចាត់ឲ្យស៊ើបសួរជំនួសចេញឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌ កាលណាដីការចាត់ឲ្យស៊ើបសួរជំនួសត្រូវប្រគល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាច ដែលមានចែងនៅក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងពិនិត្យ)[59] ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌)[60] មន្ត្រីនគបាលយុត្តិធម៌ មានសិទ្ធិក្នុងការអនុវត្ត ។

ចំពោះការអនុវត្តដីការចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិថម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមនេះតែប៉ុណ្ណោះ។ [61]មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងនៅក្នុងដីការចាត់ឲ្យស៊ើបសួរជំនួស នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយមន្ត្រីនគរបាលយុត្តិធម៌កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

### ១.៥.៣ សិទ្ធិអំណាចស៊ើបសួររបស់មន្ត្រីនគបាលយុត្តិធម៌ ក្នុងស៊ើបសួរជំនួស

វិធានទាក់ទងការស្តាប់ចម្លើយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី។

មុននឹងឆ្លើយចំពោះសំណួរសាក្សីម្នាក់ត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតប៉ុណ្ណោះ ។ ប៉ុន្តែ សាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឲ្យរួចផុតពីសម្បថ) [62]ត្រូវបានលើលែងមិនបាច់ស្បថ ។ ដើម្បីគោរពសិទ្ធិការពារខ្លួនមន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គល

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧៣
[58] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧៥
[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧៨
[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៤
[61] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧៦
[62] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៥៦

ណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ។ កាលណាស្តាប់ចម្លើយសាក្សីណាម្នាក់បានធ្វើឲ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងជួយប្រែជូន តុលាការឲ្យបានត្រឹមត្រូវ។

បុគ្គលដែលបានកោះហៅត្រូវតែចូលបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ រាយការណ៍ជូនទៅចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឲ្យចូលខ្លួនដោយមានចុះអត្តសញ្ញាណនៃ សាក្សី។ បញ្ជានេះត្រូវមានការចុះការបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងបោះត្រាផង។ បញ្ជាឲ្យចូលបង្ហាញខ្លួន អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំសាធារណៈ ដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន។

កថាខណ្ឌទី ២ ដល់ទី៥ នៃមាត្រា ៩៣ (កំណាតើហេតុលើការស្តាប់ចម្លើយ)[63] នៃក្រមនេះត្រូវ យកមកអនុវត្តលើកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី។[64]

កាលណាដីការចាត់ឲ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរស័ព្ទ ឬសារ តាមអិនធើនែត មន្ត្រីនគរបាលយុត្តិធម៌ប្រប្រាស់អំណាចដែលប្រគល់ឲ្យចៅក្រមស៊ើបសួរ ដោយវាក្យ ខណ្ឌទី ២ កថាខណ្ឌទី ១ និងកថាខណ្ឌទី២ នៃមាត្រា ១៧២[65] (កាស្តាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ ដោយចៅក្រមស៊ើបសួរ)។[66]

កំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃមាត្រា ១០៨[67](និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ)។[68]

## ១.៦ វិធានការនិរន្តរាយ

វិធានការនិរន្តរាយនេះ គឺជាសិទ្ធិអំណាចក្នុងការចេញដីការក្នុងពេលស៊ើបសួរ ការចេញដីការនោះ ចៅក្រមស៊ើបសួរអាចចេញដីការបង្គាប់ឲ្យចូលខ្លួន ដីការបង្គាប់ឲ្យនាំខ្លួន ដីការបង្គាប់ឲ្យចាប់ខ្លួន និង ដីការបង្គាប់ឲ្យឃុំខ្លួនលើជនណាម្នាក់ ឬ ជនត្រូវចោទ ។ [69]

### ១.៦.១ ដីការបង្គាប់ឲ្យចូលនាំខ្លួន

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩៣
[64] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧៩
[65] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១៧២
[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៣
[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៨
[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៤
[69] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៥

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចូលខ្លួនបាន ហើយដីកាបង្គាប់ឲ្យចូលខ្លួន គឺជាការបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ។ ដីកាបង្គាប់ឲ្យចូលខ្លួន អាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។[70]

ការជូនដំណឹងអំពីដីកាបង្គាប់ឲ្យចូលខ្លួនត្រូវឲ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគបាលយុត្តិធម៌ ឬ អាជ្ញាសាលា ។ មន្ត្រីនគបាលយុត្តិធម៌ ឬ អាជ្ញាសាលា ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន ។[71]

### ១.៦.២ ដីកាបង្គាប់ឲ្យនាំខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាបឲ្យនាំខ្លួនបាន ហើយដីកានេះ គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ។ដីកាបង្គាប់ឲ្យនាំខ្លួនអាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពក្នុងរឿងក្តី ។[72]

ចំណែកអ្នកអនុវត្តដីកានេះ គឺប្រគល់ទៅឲ្យមន្ត្រីនគបាលយុត្តិធម៌ជាអ្នកអនុវត្ត ។ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវបានផ្សព្វផ្សាយដល់ អង្គភាពនគបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ដើមដីកាត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគបាលយុត្តិធម៌ ដែលជាអ្នកទទួលបន្ទុកអនុវត្តដីកានោះ ។មន្ត្រីនគបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ពន្ធ័មុខម៉ោង ៦ ព្រឹក និង ក្រោយម៉ោង១៨ ល្ងាចបានទេ ។មន្ត្រីនគបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន ។[73]

### ១.៦.៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបាន ហើយដីកាបង្គាប់ឲ្យចាប់ខ្លួននេះ អាចត្រូវចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពពីបទល្មើស ។ចៅក្រមស៊ើបសួរ នឹងអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានលុះត្រាតែ៖

១. បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

២. បុគ្គលដែលពាក់ពន្ធ័បានគេចខ្លួនមិនដឹងថាស្ថិតនៅកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជា៖

---

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៦

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៨

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩០

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩២

- ដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ខ្លួន និង ឲ្យនាំខ្លួនបុគ្គលនោះទៅក្នុង ពន្ធនាគា ឬ មណ្ឌលឃុំខ្លួន

- ដល់មប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និង ឃុំខ្លួនបុគ្គលនោះ ។[74]

មុខពេលចេញដីការនេះ ត្រូវសុំយោបល់ ឬ ទទួលយោបល់ពីព្រះរាជាអាជ្ញា ។ ចៅក្រមស៊ើបសួត្រូវចេញដីការនេះដោយមានចែងមូលហេតុក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញាហើយព្រះរាជអាជ្ញាធានារ៉ាបរងផ្សព្វផ្សាយដីការបង្គាប់ឲ្យចាប់ខ្លួន ។ [75]

ការអនុវត្តដីការបង្គាប់ឲ្យចាប់ខ្លួន ត្រូវប្រគល់ឲ្យមន្ត្រីនគបាលយុត្តិធម៌ ។ ។ក្នុងករណីបន្ទាន់ ដីការបង្គាប់ឲ្យនាំខ្លួន ត្រូវបានផ្សព្វផ្សាយដល់ អង្គភាពនគបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីការត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគបាលយុត្តិធម៌ ដែលជាអ្នកទទួលបន្ទុកអនុវត្តដីការនោះ ។មន្ត្រីនគបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ពន្ធ័មុខម៉ោង ៦ ព្រឹក និង ក្រោយម៉ោង១៨ ល្ងាចបានទេ ។មន្ត្រីនគបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន ។[76]

កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីការបង្គាប់ឲ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះ ចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូនទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន ។[77]

### ១.៦.៤ ការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាពពេញលេញ ដែលច្បាប់ផ្តល់ឲ្យ។ ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើឬលើសពី ១ឆ្នាំ។[78] ការឃុំខ្លួនបណ្តោះអាសន្នត្រូវមានមូលហេតុដែលច្បាប់បានកំណត់ ដូចជា ៖

១. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី ។

២. ដើម្បីរារាំងកុំឲ្យមានការគាប់សង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវជន និង អ្នកសមគំនិត ។

៣. ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ ។

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

---

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩៦

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩៧

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩៩

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០២

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៤

៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ ។

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស ។[79]

ការឃុំខ្លួនបណ្តោះអាសន្ននេះ មានថិរវេលាចំពោះបទល្មើសដែលថិរវេលានោះគឺ៖

១. ចំពោះនីតីជន ចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនលើសពី ៦ ខែ បានទេ ។ប៉ុន្តែ ចៅក្រមស៊ើបសួរអាចសុំពន្យាបាន ៦ ខែ ម្តងទៀតដោយដីការសំអាងហេតុច្បាស់លាស់ ។ការពន្យាពេលនេះអាចធ្វើ បាន ២ ដងគត់ ។[80]

២. ចំពោះនីតីជន ចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នមិនលើសពី ៤ ខែ បានទេ ។ប៉ុន្តែ ចៅក្រមស៊ើបសួរអាចសុំពន្យាការឃុំខ្លួនបណ្តោះអាសន្នបានតែម្តងគត់មិនឲ្យលើសពី ២ ខែ ដោយមានដីការសំអាង ហេតុច្បាស់លាស់ ។ [81]

៣. ចំពោះការឃុំខ្លួននៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬ ឧក្រិដ្ឋសង្គ្រាម ការឃុំ ខ្លួនបណ្តោះអាសន្ន មិនលើសពី ១ ឆ្នាំបានទេ ។ចៅក្រមស៊ើបសួរអាចពន្យាបាន ម្តង ១ឆ្នាំ ដោយមានដីការសំអាង ហេតុច្បាស់លាស់ ។ការពន្យាពេលនេះបាន ២ ដងគត់។ [82]

ចំពោះអនីតិជន អាយុក្រោយ ១៤ ឆ្នាំ ការឃុំខ្លួនមិនមានឡើយ។ [83]ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អ នីតិជននេះឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវបានប្រគល់ទៅ មជ្ឈមណ្ឌល អប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេក្តីសម្រេចរបស់តុលាការ ។

**១.៦.៥ ដីការបង្គាប់ឲ្យឃុំខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីការបង្គាប់ឲ្យឃុំខ្លួន [84]ដីការបង្គាប់ឲ្យឃុំខ្លួនគឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទ ។[85]

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៥
[80] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៨
[81] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៩
[82] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១០
[83] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១២
[84] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៩
[85] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២២០

ចៅក្រមស៊ើបសួរអាច នឹងចេញដីការបង្គាប់ឲ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីការសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ។ ការអនុវត្តដីការបង្គាប់ឲ្យឃុំខ្លួននេះ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីការបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែបានទទួលការឲ្យដំណឹងការដោះលែងឲ្យមានសេរីភាព ។[86]

## ១.៧ ការបិទការស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវរៀបចំ កិច្ចនីតិវិធីក្នុងបិទការស៊ើបសួររបស់ខ្លួន ដោយជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីនិង មេធាវី ។ បន្ទាប់មកចៅក្រមស៊ើបសួរ ត្រូវចេញដីការដំណោះស្រាយ ។

### ១.៧.១ ដីកាដំណោះស្រាយ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ចៅក្រមស៊ើបសួរជូនពណ៌ មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ ពីរ (២) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យព្រះរាចអាជ្ញាពិនិត្យ។[87]

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះព្រះរាជអាជ្ញាត្រូវ ធ្វើតាមមាត្រា ១៣២ (ការស្នើរសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា) ។[88]

ក្នុងរយះពេល ១៥ (ដប់ប្រាំថ្ងៃ) ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១ (មួយ) ខែ ក្នុង ករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសុំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយ មានដីកាសនិដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលោព្រះរាជអាជ្ញាទទួលបានសំ ណុំរឿង។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូច ចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីការសន្និដ្ឋានស្ថាពរជាលាយលក្សណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាអាជ្ញាអាច ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីការដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនរឿង ទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់។ ប្រសិនបើយល់ឃើញថាអំពើនោះ បទឧក្រិដ្ឋ បទមជ្ឈឹម ឬបទហុ ចៅក្រមស៊ើបសួរបញ្ជូនជន ត្រូវចោទទៅមុខតុលាការជំនុំជម្រះ ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទ ល្មើសតាមច្បាប់។ ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ:

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២២២

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៦

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣២

1. អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬ បទលហុ។
2. ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់។
3. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វ កិច្ចគោរព តាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំ ជម្រះ ចំពោះអំពើរមួយ ចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើរដទៃទៀត។

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី។[89]

### ១.៧.២ ការបើកការស៊ើបសួរជាថ្មីលើបន្ទុកថ្មី

ការបើកការ ស៊ើបសួរជាថ្មីនូវការស៊ើបសួរលើបន្ទុកថ្មីនោះ មានន័យថាក្រោយពេលដែលដីការបស់ចៅក្រម ស៊ើបសួរ ឬ សាលដីការបស់សភាស៊ើបសួរដែលបានលើកលែងចោទប្រកាន់ចូលជាស្ថាពរ ហើយនោះមានលេច ឡើងនូវបន្ទុកថ្មី ដែលចៅក្រមស៊ើបសួររកឃើញនោះ ការស៊ើបសួរអាចត្រូវបានបើកឡើងវិញ តាមគំនិតផ្តើមឡើង របស់ព្រះរាជអជ្ញា ។ ព្រះរាជអាជ្ញាអាចចាប់គំនិត និង ស្នើសុំឲ្យមានការបើកការស៊ើបសួរថ្មីមួយទៀត ដែលនៅលើ បន្ទុកថ្មីដែលរកបានឃើញដោយចៅក្រមស៊ើបសួរនោះ ។ [90]

### ១.៧.៣ ការបញ្ជូនដើម្បីបើកសវនាការជំនុំជំម្រះ

ការបញ្ជូនរឿងទៅជំនុំជំម្រះ គឺជាការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ ប្រសិនបើចៅក្រមស៊ើបសួរ គាត់ បានសម្រេចចេញដីកាសម្រេចមួយដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនរឿងជាបន្ទាន់ទៅ ប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះជាកាលបច្ចេទពេលវេលា ។[91]

ការកំណត់ពេលវេលាដើម្បីបើកសវនាការនោះ គឺត្រូវកំណត់ឡើងដោយប្រធានសភាស៊ើបសួរ ។

## ផ្នែកទី ២ សភាស៊ើបសួរ

សភាស៊ើបសួរ គឺជាអង្គភាពស៊ើបសួរជាន់ខ្ពស់ដែលស្ថិតអមនៅសាលាឧទ្ធរណ៍ ហើយមាននាយឋានានុក្រម លើអង្គភាពស៊ើបសួរដែលស្ថិតអមនៅសាលាដំបូង រាជធានី ខេត្ត។សភាស៊ើបសួរ គឺមានសមត្ថកិច្ចទទួលបណ្តឹង នានាដែលកើតចេញពីការស៊ើបសួររបស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ។

[89] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៨៧

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៥១

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៥០

### ២.១ បណ្ដឹងឧទ្ធរណ៍ចំពោះដីការរបស់ចៅក្រមស៊ើបសួរ

នៅពេលមានបណ្ដឹងពីព្រះរាជអាជ្ញាចំពោះដីការសម្រេចណាមួយរបស់ចៅក្រមស៊ើបសួរនោះគេហៅ បណ្ដឹងឧទ្ធរណ៍ចំពោះដីការរបស់ចៅក្រមស៊ើបសួរ ។

#### ២.១.១ បណ្ដឹងឧទ្ធរណ៍ចំពោះដីការសម្រេចដោយអគ្គព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញា ឬ ជនត្រូវចោទ ឬ ដើមបណ្ដឹង

អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅ ក្រមស៊ើបសួរបាន។[92] បណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ:

–ដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៣[93](ការស្នើរសុំឲ្យបំពេញកិច្ចដោយជនជាប់ចោទ)

–ដីការមិនព្រមប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា១៦១[94] (ការប្រគល់វត្ថុដែលចាប់យកឲ្យតៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ [95](ការប្រគល់វត្ថុដែលចាប់យកឲ្យតៅម្ចាស់ដើមវិញ)

–ដីកាបដិសេដពាក្យសុំឲ្យធ្វើកោសលវិច័យបន្ថែម ដូចដែលមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា ១៦២ [96](ភាពចាំបាច់នៃការធ្វើកោសលវិច័យ)

–ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសល់វិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យ ដូចដែលមាន ចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ [97](ការជូនដំណឹងអំពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យ) និង

–ដីកាស្ដីពីរឿងឃុំខ្លួនបណ្ដោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលមានចែងក្នុង ផ្នែកទី ៥ ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន និងផ្នែកទី ៧ ស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃជំពូកទី ៣ស្ដីពីវិធានការនិរន្តរាយក្នុងមាតិកាទី ១ នៃកន្លីនេះ និងមាត្រា ២៤៩ (សេចក្ដីសម្រេចនៃ ដីកាដំណោះស្រាយទាក់នឹងការឃុំខ្លួនបណ្ដោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ)។[98]

---

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៦៦
[93] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៣
[94] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦១
[95] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៨
[96] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦២
[97] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧០
[98] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៦៧

បណ្តឹងឧទ្ធរណ៍ចំពោះដីការចៅក្រមស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ:

–ដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៤ [99](ការស្នើរសុំឲ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី)

–ដីកាមិនព្រស៊ើបសួរដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នសមាត្រា ១៣៩ [100](ការបញ្ជូនដំណឹង ទៅព្រះរាជអាជ្ញា)

–ដីកាកំណត់ចំនួនប្រាក់កក់ ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៤០ [101](ការបង់ប្រាក់ តម្កល់ទុក)

–ដីការប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដូចដែលមាន ចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់) នៃក្រមនេះ

–ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងមាត្រា ១៤១[102](បណ្តឹងដោយបំ ពាន រ បណ្តឹងដោយអូសបន្លាយពេលវេលា)

–ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យក ទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១[103](ការប្រគល់វត្ថុដែលចាប់យកឲ្យ ទៅម្ចាស់ដើមវិញ ដោយចៅក្រមស៊ើបសួរ) និង មាត្រា ២៤៨[104](ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ)

–ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសល់វិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២នៃមាត្រា ១៦២[105](ភាពចាំបាច់នៃការធ្វើកោសល់វិច័យ)

–ដីកាបដិសេធសុំឲ្យធ្វើកោសល់វិច័យបន្ថែម ឬ សុំឲ្យធ្វើប្រតិកោសលវិច័យដូចដែលមានចែងក្នុង កថាខណ្ឌទី ៧ នៃមាត្រា ១៧០[106] (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ)

–ដីកាដំណោះស្រាយដូចដែលមានចែងក្នុងមាត្រា ២៤៧ (ដីកាដំណោះស្រាយ) ។

---

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៤
[100] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៩
[101] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤០
[102] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤១
[103] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦១
[104] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៨
[105] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៦២
[106] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៧០

រយៈពេលនៃការប្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូងជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។[107]

### ២.១.២ ការបន្តស៊ើបសួរក្នុងករណីមានបណ្ដឹងឧទ្ធរណ៍

ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ចំពោះដីកាណាមួយក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់ប្រធានស៊ើបសួរ។ សេចក្ដីសម្រេចនេះមិនអាចតវ៉ាបានឡើយ ។[108]

### ២.១.៣ បណ្ដឹងឧទ្ធរណ៍ចំពោះដីការលើកលែងការចោទប្រកាន់

កាលណាទទួលបណ្ដឹងឧទ្ធរណ៍ ចំពោះដីការលើកលែងការចោទប្រកាន់ សភាស៊ើបសួរសម្រេចតាមផលវិបាកនៃមោឃកម្ម។[109] ក្រោយពីធ្វើមោឃកម្មរួច សភាស៊ើបសួរអាចៈ

- បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬ
- បន្តស៊ើបសួរដោយខ្លួនឯងលើរឿងនោះ។[110]

ការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព កាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំបណ្ដោះអាសន្ន ជនត្រូវចោទនោះ ត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតផុតរយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអជ្ញា ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី។

ត្រូវធ្វើដូចគ្នានេះផងដែរ ចំពោះដីកាលើកលែងចោទប្រកាន់ កាលណាដីកានេះមានអនុភាពនាំឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំ។ ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាដើម្បីដោះលែងឲ្យនៅក្រៅឃុំឬលើកលែងការចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍។[111]

## ២.២ ការឃុំខ្លួនបណ្ដោះអាសន្ន

### ២.២.១ មោឃភាព

---

[107] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៦៨

[108] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧៥

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧៧

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨១

[111] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧៦

ភាពដែលមិនអាចទទួលយកបាននៃពាក្យប្តឹងសុំមោឃកម្ម សភាស៊ើបសួរអាចប្រកាសមិនទទួលពាក្យប្តឹងសុំឲ្យមោឃកម្ម នៅក្នុងករណីដូចតទៅ

- ពាក្យប្តឹងសុំគ្មានសំអាងហេតុ
- ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍
- ពាក្យប្តឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្តែង

សេចក្តីសម្រេចរបស់សភាស៊ើបសួរ មិនអាចតវ៉ាបានទេ។ កាលណាពាក្យប្តឹងសុំត្រូវបានប្រកាសមិនអាចទទួលបានទេ សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ។[112]

**២.២.២ អំណាចផ្ទាល់ខ្លួនរបស់ប្រធានសភាស៊ើបសួរ**

អំណាចរបស់ប្រធានសភាស៊ើបសួរ ប្រធានសភាស៊ើបសួររ៉ាប់រងលើការប្រព្រឹត្តិទៅដ៏ល្អនៃមន្ទីរស៊ើបសួរ នៃចៅក្រមស៊ើបសួរ។ ប្រធានសភាស៊ើបសួរ ផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខខណ្ឌនៃការអនុវត្តបទបញ្ញត្តិស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដីកាតុលាការផ្សេងៗ ដីកាចាត់ឲ្យស៊ើបសួរជំនួយ និងកោសលវិច័យ។ ប្រធានសភាស៊ើបសួររ៉ាប់រងកុំឲ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផល ប្រធានសភាស៊ើបសួរអាចចុះទៅធ្វើអធិការកិច្ចនៅក្នុងមន្ទីរស៊ើបសួរ ។[113]

គ្រប់អធិការកិច្ចនៃមន្ទីរស៊ើបសួរ ដោយប្រធានសភាស៊ើបសួរ ត្រូវតែធ្វើរបាយការណ៍ផ្ញើ ទៅប្រធានសាលាឧទ្ធរណ៍។[114]

បណ្តឹងសុំបិទសំណុំរឿង នៅពេលផុតចិរវេលា ១ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល ១ខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរដែលធ្វើអធិបញ្ញាដល់ចៅក្រមស៊ើបសួរឲ្យសម្រេច។ លុះផុតចិរវេលា ១ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឲ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល ១ ខែ គិតពីការទទួលពាក្យប្តឹងសុំចៅក្រមស៊ើបសួរត្រូវតែសម្រេច ករណីប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ញាដល់ចៅក្រមស៊ើបសួរឲ្យសម្រេច ។[115]

[112] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧៩
[113] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨៣
[114] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨៥
[115] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨៦

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានកាសិក្សាច្បាប់ លើច្បាប់ដែលចូលជាធរមានស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលបានតាក់ តែងឡើងដោយមានអនុម័តពីអង្គការនីតិបញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជារួចមកបានឲ្យខ្ញុំយល់ដឹងពីសមត្ថកិច្ច សិទ្ធិអំណាច និងតួនាទី របស់នគរបាលយុត្តិធម៌ និងអង្គការអយ្យការក្នុងការស៊ើបអង្កេត និងចៅក្រមស៊ើបសួរក្នុងការអនុវត្តមុខងាររបស់ខ្លួន ក្នុងការស៊ើបសួរ ។ចំណេះដឹងទាំងអស់នេះបានតម្រូវឲ្យខ្ញុំបាទ ចងក្រងជាសារណាមួយក្រោមប្រធានបទស្តីពី **នីតិវិធីស៊ើបអង្កេត និង ការស៊ើបសួរ** ដើម្បីបញ្ចប់ការសិក្សាបរិញ្ញាបត្រ។

តាមរយៈសារណានេះ បានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងកិច្ចការងារ រវាងនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ដែលមានប្រទាក់គ្នាជាប់ឥតដាច់ក្នុងការស៊ើបអង្កេត និងស៊ើបសួរស្វែងរកការពិតនៃដំណើរការរឿងព្រហ្មទណ្ឌ។ ចាប់តាំងពីដំណាក់កាលដំបូងនៃការស៊ើបអង្កេតស្វែងរកបទល្មើស ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នោះ ហើយអាចបើការស៊ើបអង្កេតស្វែងរកភស្តុតាង ដើម្បីឲ្យការពិតលេចចេញមក ដោយធ្វើការចោទសួរ ទៅលើជនសង្ស័យ ក៏ដូចជាជនដែលជាប់ពាក់ព័ន្ធ និងធ្វើកំណត់ហេតុ ដើម្បីកសាងសុំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញា ។ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានធ្វើកំណត់ហេតុកសាងសុំណុំរឿងរួចមកមន្ត្រីនគរបាលយុត្តិធម៌ធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាអាជ្ញា ដើម្បីធ្វើចំណាត់ការព្រមទាំងនាំខ្លួនជន សង្ស័យឲ្យទៅបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញាផងដែរ។ ព្រះរាជអាជ្ញាធ្វើចំណាត់ការទៅលើសំណុំរឿងដោយ តម្កល់រឿងទុកឥតចាត់ការ ឬសម្រេចធ្វើការចោទប្រកាន់ទៅលើជនល្មើស ដោយផ្អែកលើមូលដ្ឋានច្បាប់។ បន្ទាប់មកទៀត ត្រូវធ្វើការពិនិត្យមើលទៅលើធាតុផ្សំនៃបទល្មើស រួមមាន ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ដើម្បីធ្វើការថ្លឹងថ្លែងមុននិសម្រេចការចោទប្រកាន់ ឬតម្កលរឿងទុកឥតចាត់ការ។ ក្នុងករណីបទមជ្ឈឹម ឬបទលហុ ដែលព្រះរាជអាជ្ញាអាច ចេញដីការសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរទៅចៅក្រមស៊ើបសួរតែម្តង។ ចៅក្រមស៊ើបសួរត្រូវមានអព្យាក្រឹត្យក្នុងការស៊ើបសួរប្រមូលភស្តុតាង ទាំងដាក់បន្ទុក និងដោះបន្ទុក ដើម្បីធានាឲ្យមានតុល្យភាពរវាងការបង្ក្រាប និងគោរពសិទ្ធិជនត្រូវចោទ ។

សរុបមក នៅក្នុងនីតិវិធី នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាពិតជាមានសារៈសំខាន់ណាស់ ព្រោះវា គឺជានីតិវិធី ដែលធ្វើឡើង ដើម្បីស្វែងរកការពិតនៃរឿងមុននិងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ការ ស៊ើបអង្កេតនេះត្រូវធ្វើឡើងដោយម៉តចត់ និងត្រឹមត្រូវក្នុងគោលបំណងធ្វើឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីស្វែងរកការ ពិត យុត្តិធម៌ ដោយអាចធានាបាននូវការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ស្របតាមបញ្ញត្តិដែលមានចែងក្នុង រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

យោងទៅតាមការសង្កេតឃើញសកម្មភាពអនុវត្ត នីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌសព្វថ្ងៃនេះ គឺមាន ភាពល្អប្រសើរច្រើនដោយសារតែមន្ត្រី ដែលមានសមត្ថកិច្ចស៊ើបអង្កេតភាគច្រើនគោរពទៅតាមតួនាទីខ្លួនយ៉ាងល្អ និង ប្តេជ្ញាចិត្តធ្វើការបម្រើប្រជាពលរដ្ឋទៅតាមដែនដីរបស់ខ្លួន ដើម្បីធានាបង្ការមិនឲ្យមានបទល្មើស និងបង្រ្កាបបទល្មើស នានា ដែលកើតមាននៅក្នុងសង្គម ដោយអនុវត្តទៅតាមក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងមានភាពល្អប្រសើរ ក្នុងនោះក៏មានភាពខ្វះចន្លោះផងដែរ។ ដូចនេះ ដើម្បីធ្វើការស៊ើបអង្កេតស្វែងរកបទល្មើសទទួលបាននូវភាពល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព ខ្ពស់នោះ ក្រសួងយុត្តិធម៌ ឬ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយធ្វើការកែលម្អ និងបំពេញទៅលើចំណុចខ្វះខាតមានដូចតទៅ

1) រៀបចំឲ្យមានការបណ្តុះបណ្តាលជំនាញ និងវិធីសាស្ត្រល្អៗ ក្នុងការស៊ើបអង្កេតដល់មន្ត្រី ដែលមានសមត្ថកិច្ច ក្នុងការស៊ើបអង្កេត ដើម្បីឲ្យការស៊ើបអង្កេតទទួលបាននូវប្រសិទ្ធភាព និងច្បាស់លាស់។

2) ផ្តល់សម្ភារៈ ឬឧបករណ៍បច្ចេកទេស សម្រាប់ធ្វើការកោសលវិច្ឆ័យដល់មន្ត្រី ដែលមានសមត្ថកិច្ចក្នុងការស៊ើប អង្កេត សម្រាប់ធ្វើការស្រាវជ្រាវស្វែងរកភស្តុតាង ឬឧបករណ៍សម្រាប់ស្កេនក្រយៅដៃ។

3) ផ្តល់ប្រាក់ឧបត្ថម្ភ ជាកញ្ចប់បេសកកម្មចុះទៅធ្វើការស្រាវជ្រាវផ្សេងៗ របស់នគរបាល ក៏ដូចជាមន្ត្រីពាក់ព័ន្ធក្នុង ការស៊ើបអង្កេត ដើម្បីឲ្យការស៊ើបអង្កេតឲ្យមានសកម្មភាព ក៏ដូចជាការលើកទឹកចិត្តដល់មន្ត្រីពាក់ព័ន្ធដែល មានស្នាដៃក្នុងការបំពេញមុខងាររបស់ខ្លួន។

ម្យ៉ាងទៀត ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរដោយផ្ទាល់ ជៀសវាងឲ្យក្រឡាបញ្ជីជាអ្នកស៊ើបសួរជំនួស ជាពិសេសនោះ គឺត្រូវគោរពតួនាទីរបស់ខ្លួនទៅតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិ វិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

ប្រសិនបើ ចំណុចខាងលើនេះត្រូវបានបំពេញពិតជាល្អខ្លាំងណាស់។ ខ្ញុំជឿជាក់ថា ការស៊ើបអង្កេតស្វែងរកជនល្មើស ប្រាកដទទួលបានផលល្អ ហើយប្រជាពលរដ្ឋច្បាស់ជាទទួលបាន នូវយុត្តិធម៌ ពិសេសជាងនេះទៅទៀត នោះគឺ សង្គមទទួលបាននូវភាពល្អប្រសើរ ដោយគ្មានការរំលោភសិទ្ធិគ្នា កាត់បន្ថយអំពើរល្មើសក្នុងសង្គម ដែលធ្វើឲ្យសង្គម មានសុវត្ថិភាព សន្តិភាព និងប្រកបទៅដោយភាពរីកចម្រើនជាមិនខាន។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១០ ខែសីហាឆ្នាំ ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ៣០ ខែវិច្ឆិកាឆ្នាំ ២០០៩
- សៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់លោកសាស្ត្រាចារ្យ អៀងសំណាង បោះពុម្ពឆ្នាំ ២០១៥
- ឯកសារបានមកពីការផ្សព្វផ្សាយច្បាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ រៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយទូរទស្សន៍ជាតិកម្ពុជា (ទទក)
- ប្រភេទដីកាមួយចំនួនរបស់អយ្យការនិងចៅក្រមស៊ើបសួរដែលយកមកប្រើប្រាស់នៅក្នុងនីតិវិធីនៃការស៊ើបអង្កេតនៅសាលាដំបូង។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
លេខ៖ ៣២០ "ត"ព្រទ

## ដីកាបង្គាប់ឲ្យចូលខ្លួន

យើង _ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៤៤៨៨ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ ៤៥៣៩ អ.យ.ត ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

### បង្គាប់មក

ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៣៨ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

ឲ្យចូលទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៩និង០០នាទី [ព្រឹក] នៅបន្ទប់ "ត" ជាន់ទី៤ នៃសាលាដំបូងរាជធានីភ្នំពេញជាកំណត់។

ដើម្បីសាកសួរយកព័ត៌មានផ្សេងៗដែលជាប់ទាក់ទងនឹងដំណើររឿង៖ ប្តឹងបរិហារបង្កាច់កេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣១១ និងមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ ។

ថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

នៅរាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

បញ្ជាក់៖ ករណីរឹងទទឹងមិនចូលមកបង្ហាញខ្លួន តាមការកំណត់ខាងលើនេះទេ យើងនឹងចេញដីកាបង្គាប់ឲ្យនាំខ្លួន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ម"

លេខ: 28315 "ម" ដដ

# ដីកាលើកលែងចោទប្រកាន់

យើង អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជា

ចៅក្រមស៊ើបសួរ ដោយមានលោកស្រី ជាក្រឡាបញ្ជី។

- បានឃើញ បញ្ញត្តិមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤២២ អ.យ.ថ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៦០ អ.យ.ថ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹងជនត្រូវចោទដូចខាងក្រោម៖

ឈ្មោះ ហៅ ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ និស្សិត ទីកន្លែងកំណើត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៤៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលើវ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" ជានីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវ ១៣៨ កែងផ្លូវ ២៥៩ ស្ថិតនៅក្រុម ២៨ ភូមិ ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ (ក្រៅឃុំ)

- ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ ២២៩៧ "ម" ដពស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។
- ដីកាបង្គាប់ឱ្យដោះលែងលេខ ៣២៧២ "ម" ដឃដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។

- ជនរងគ្រោះ ឈ្មោះ ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៧៥ ផ្លូវ២១៧ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- មេធាវី ឈ្មោះ អត្តលេខ ៧៧៥ មេធាវី ឈ្មោះ មេធាវី ឈ្មោះ មេធាវី ឈ្មោះ អត្តលេខ ៨៥៦ មេធាវី ឈ្មោះ អត្តលេខ ២១៦៦T មេធាវី ឈ្មោះ និង មេធាវី ឈ្មោះ ជាសហមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ។
- មេធាវី ឈ្មោះ អត្តលេខ ៤២២ មេធាវី ឈ្មោះ និងមេធាវី ឈ្មោះ ជាសហមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
មន្ទីរស៊ើបសួរ "ខ"
លេខ: ១៥៧៥៩/២០

ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ
ការិយាល័យ...
ចូល លេខ ៥០ ថ្ងៃទី ០៧ ខែ ... ឆ្នាំ ២០២០

# ដីកាបង្គាប់ឲ្យនាំខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ មាត្រា ១៨៩ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៩០៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ: ២៣៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៩៦៥ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ ដែលចោទប្រកាន់ឈ្មោះ [redacted] ភេទប្រុស អាយុ៦០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្រពាំងពើក ឃុំកាត់ភ្លុក ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "ស" មានកូន០៨នាក់ ទោសពីមុនគ្មាន ជាតិជន។

ដែលបានចោទប្រកាន់ពីបទ: **កាប់រានព្រៃ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដកបំផ្លាញបង្គោលព្រំប្រទល់ព្រៃឈើ និងដកបំផ្លាញកូនឈើដែលបានដាំ(កូនបេង)** ប្រព្រឹត្តនៅភូមិអូង ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ១៩៨៨, ឆ្នាំ១៩៩៣, ឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិ និងផ្តន្ទាទោសតាម**មាត្រា៩៥ ចំណុចទី៣, មាត្រា ៩៧ ចំណុចទី៦ និងមាត្រា៩៥ ចំណុចទី២** នៃច្បាប់ស្តីពីព្រៃឈើ។

## សំអាងហេតុ

-ជនត្រូវចោទឈ្មោះ [redacted] ត្រូវបានតំណាងអយ្យការត្រូវបានចោទប្រកាន់ពីបទ កាប់រានព្រៃ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដកបំផ្លាញបង្គោលព្រំប្រទល់ព្រៃឈើ និងដកបំផ្លាញកូនឈើដែលបានដាំ(កូនបេង) តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:៩៦៥ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១។

-ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឲ្យចូលខ្លួនលើឈ្មោះ [redacted] ដើម្បីចូលខ្លួនមកឆ្លើយបំភ្លឺ ចំពោះមុខចៅក្រមស៊ើបសួរតាមនីតិវិធី ប៉ុន្តែមិនទទួលបានលទ្ធផល។

-ដើម្បីធានាដល់ការស៊ើបសួរឲ្យបានពេញលេញ គប្បីសម្រេចនាំខ្លួនឈ្មោះ [redacted] មកចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីបំភ្លឺការពិតក្នុងរឿងក្តីនេះ។

## ហេតុដូច្នេះសម្រេច

១-បង្គាប់ឲ្យនាំខ្លួនជនត្រូវចោទឈ្មោះ [redacted] ដែលមានអត្តសញ្ញាណដូចខាងលើនេះ មកសាលាដំបូងខេត្តកំពង់ស្ពឺ។

២-ដីកាបង្គាប់ឲ្យនាំខ្លួននេះ មានសុពលភាពរយៈពេល ០១ខែ គិតចាប់ពីថ្ងៃបានទទួលដីកានេះ។

៣-បង្គាប់កងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីចាត់ការតាមច្បាប់។

ថ្ងៃ [illegible] ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កំពង់ស្ពឺ, ថ្ងៃទី [illegible] ខែសីហា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

[redacted]

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តព្រះសីហនុ
សំណុំរឿងលេខ: ១១៦០/២៩.១០.២០២០
លេខស៊ើបសួរ: ១០២៩ ព្រក/២៩.១០.២០២០
លេខ: 128 តឃ៥/២០

# ដីកាបង្គាប់ឲ្យឃុំខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូង ខេត្តព្រះសីហនុ។

បានឃើញ បានឃើញមាត្រា២១៩,មាត្រា២២០,មាត្រា២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៧៨ អយក/២០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តព្រះសីហនុ បានសម្រេចបើកការស៊ើបសួរលើ៖

ឈ្មោះ [redacted] ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ ម្ចាស់សណ្ឋាគារសមុទ្រមាស មានទីកន្លែងកំណើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅសណ្ឋាគារសមុទ្រមាស សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] ហៅ [redacted] "លែងលះ" មានកូន០៣នាក់ ប្រវត្តិនៃការផ្តន្ទាទោស គ្មាន ជាតិពិជ គ្មាន *ជនត្រូវចោទត្រូវបានចាប់ខ្លួននៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០។*

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **អំពើផលិតរូបភាពនៃបុគ្គលនៅក្នុងទីកន្លែងឯកជនដោយគ្មានការព្រមព្រៀង និងអំពើផលិតរូបភាពអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ** ប្រព្រឹត្តនៅបន្ទប់ជួល ក្រុម១៩ ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ មាត្រា ៣០២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៥ មាត្រា៣៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

បានឃើញ មាត្រា២០៣ ,មាត្រា២០៤ ,មាត្រា២០៥ និងមាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ: 126..... តឃ៥/២០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

## ហេតុដូច្នេះសម្រេច

១-បញ្ជាឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកំលាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទ ដែលមានឈ្មោះ [redacted] ភេទស្រី អាយុ៤៨ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ទៅឃុំខ្លួននៅពន្ធនាគារ ខេត្តព្រះសីហនុ ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

២-រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន គិតចាប់ពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ និងមិនឲ្យហួសពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ លើកលែងតែមានដីកាបង្គាប់ឲ្យពន្យាពេលឃុំខ្លួន ឬដីកាបង្គាប់ឲ្យពន្យាពេលឃុំខ្លួន ឬដីកាបង្គាប់ឲ្យរក្សាទុកជនជាប់ចោទក្នុងឃុំរង់ចាំការជំនុំជម្រះ ។

៣-បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តព្រះសីហនុ ទទួលយកជននេះនិងឃុំខ្លួនជននេះរហូតដល់មានបញ្ជាថ្មី សម្រេចផ្សេងពីនេះ។

៤-បង្គាប់ឲ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈទាំងអស់ នៅពេលត្រូវបានបង្ហាញដីកានេះត្រូវសហការ អនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់ ។

ថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០
ចៅក្រមស៊ើបសួរ

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ១០៧ ដចខ

# ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង ចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌ លេខ ៥៨៦៧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ។

**បានឃើញ** សំណុំរឿងស៊ើបសួរ លេខ ១០២៣ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ។

**បានឃើញ** សំណុំរឿងជំនុំជម្រះ លេខ ៣១៤០ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៣១៣ "ខ១" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ ។

**សំអាងហេតុ**

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ឃើញថា ៖ ឈ្មោះ ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរពាណិជ្ជករ ទីកន្លែងកំណើតនៅភូមិគីឡូម៉ែត្រលេខ៦ ស្រុកឬស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៤៧បេ ផ្លូវលេខ៣៥២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់) ប្តីឈ្មោះ (រស់) ជានីតិជន ទោសពីមុនគ្មាន ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ចេញសាលក្រមកំបាំងមុខលេខ ៣១៣ "ខ១" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ ដោយវិនិច្ឆ័យសេចក្តីផ្តន្ទាទោសជននេះដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

តាមសាលក្រមកំបាំងមុខលេខ ៣១៣ "ខ១" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ ដែលមានអត្តសញ្ញាណខាងលើនេះផងដែរ ។

**<u>ហេតុដូច្នេះសម្រេច</u>**

១-បង្គាប់ឲ្យចាប់ខ្លួនពិរុទ្ធជនឈ្មោះ ដែលមានអត្តសញ្ញាណខាងលើ ។

២-បញ្ជាដល់កងកម្លាំងសាធារណៈទាំងអស់ឲ្យស្រាវជ្រាវរកចាប់ និងឃុំខ្លួនឈ្មោះខាងលើនេះទៅបង្ហាញខ្លួននៅមុខព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនដើម្បីចាត់ការតាមច្បាប់ ។

ថ្ងៃ សុក្រ ១២ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តសៀមរាប
សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨៨២
ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

អធិការដ្ឋាននគរបាលក្រុងសៀមរាប
ចូល លេខ [illegible]
ថ្ងៃទី 07 ខែ 02 ឆ្នាំ២០21

# ដីកាកោះ

យើង [redacted] តំណាងអយ្យការ អមសាលាដំបូង ខេត្តសៀមរាប។

កោះហៅឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៤ ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ។

ឲ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្ត ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ២:៣០ នាទីរសៀល (បន្ទប់លេខៈ ក០៥)។

ដើម្បី៖ សាកសួរបំភ្លឺលើការដាក់ពាក្យប្ដឹងរបស់ឈ្មោះ [redacted] ពីដំណើររឿង "ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស" ប្រព្រឹត្តនៅចំណុចភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ។

សាមីខ្លួន ត្រូវចូលមកបំភ្លឺតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកឯកសារផ្សេងៗដែលទាក់ទងនិងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃចន្ទ ៨រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាប, ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១
ព្រះរាជអាជ្ញារង

[redacted]

យើង [illegible] [redacted] បានប្រគល់លិខិតអញ្ជើញនេះឱ្យឈ្មោះ [redacted]
ទីលំនៅសព្វថ្ងៃ ផ្ទះ ភូមិ [illegible] ឃុំ/សង្កាត់ [illegible] ស្រុក/ខណ្ឌ សៀមរាប
ខេត្ត/រាជធានី សៀមរាប នៅថ្ងៃទី 07 ខែ 02 ឆ្នាំ2021 ផ្ទាល់រួចហើយ ដោយយើងបានទុកច្បាប់ដីកានេះមួយច្បាប់ឱ្យសាមីខ្លួន ហើយប្រាប់ថាឱ្យសាមីខ្លួន ប្រគល់ច្បាប់ដីកានេះជាប់ ក្រឡាបញ្ជី នៅពេលខ្លួនចូលទៅដល់តុលាការ ឬ អយ្យការ។

អ្នកទទួលលិខិត
ហត្ថលេខា ឬ ផ្តិតម្រាមដៃ

[redacted]

អ្នកប្រគល់

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអម
សាលាឧទ្ធរណ៍ត្បូងឃ្មុំ
សំណុំរឿងសាលាព្រហ្មទណ្ឌលេខ: ១៣៦
ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០២១

# ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ

យើង [redacted] រាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ

បង្គាប់មកឈ្មោះ [redacted] ភេទប្រុស អាយុ៣៦ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិឬស្សីស្រុក ឃុំស្រាន់ ស្រុករវៀង ខេត្តព្រះវិហារ។

ឱ្យចូលមកកាន់៖ សាលាឧទ្ធរណ៍ត្បូងឃ្មុំ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង០៨ ព្រឹក នៅបន្ទប់សវនាការទី ១ ជាកំណត់។

ដើម្បីជំនុំជម្រះលើ៖ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] បានប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ០១ (ង) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ ២០២១ របស់សាលាដំបូងព្រះវិហារ។

ជាប់ចោទពីបទ ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍។

សមាសភាពពេលបើកជំនុំជម្រះ

| | | |
|---|---|---|
| -លោកស្រី | [redacted] | ប្រធានក្រុមប្រឹក្សា |
| -លោក | [redacted] |ចៅក្រមប្រឹក្សា |
| -លោក | [redacted] | ចៅក្រមប្រឹក្សា |
| -លោក | [redacted] | តំណាងមហាអយ្យការ |
| -លោក | [redacted] | ក្រឡាបញ្ជីសវនាការ |

ថ្ងៃ ... ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
ត្បូងឃ្មុំ ថ្ងៃទី ... ខែ ឧសភា ឆ្នាំ២០២១
**ព្រះរាជអាជ្ញា**

[redacted]

យើង... [redacted] ...
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ [redacted] ...
ទីលំនៅភូមិ...ឃុំ-សង្កាត់...
ស្រុក-ខណ្ឌ...រាជធានី-ខេត្ត...
នៅថ្ងៃទី...១៥...ខែ...ឧសភា...ឆ្នាំ២០២១ រួចហើយ។
ហើយបានប្រាប់ថាឱ្យប្រគល់ដីកាកោះនេះដល់ក្រឡាបញ្ជី
នៅពេលដែលខ្លួនចូលទៅដល់។

អ្នកទទួល | អ្នកប្រគល់

[redacted] [redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៥១៦
ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០២០

# ដីកាកោះ

**យើង** [redacted] **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

សូមអញ្ជើញឈ្មោះ [redacted] ភេទប្រុស ជនជាតិខ្មែរ កើតថ្ងៃទី៣០.៦.១៩៨៧ អាសយដ្ឋានផ្ទះលេខ៣៦ ភូមិរំចេក៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ជាជនសង្ស័យ ។

**ឲ្យចូលទៅកាន់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ( ជាន់ទី ២ បន្ទប់ **ឈ** )
នៅថ្ងៃទី២៦ ខែ មករា ឆ្នាំ២០២១ វេលាម៉ោង ១៤:០០ នាទីរសៀល ។

**ដើម្បីចូលមកឆ្លើយបំភ្លឺពីដំណើររឿងៈ បរិហារកេរ្តិ៍ជាសាធារណៈ ជេរប្រមាថជាសាធារណៈ និងញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍** តាមពាក្យបណ្តឹងរបស់ដើមបណ្តឹងលោកសោម សូរីដា ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ចុះថ្ងៃទី០១.១២.២០២០ ។

សាមីខ្លួនត្រូវអញ្ជើញមកតាមដីកាកោះ នេះឲ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ ព្រមទាំងយកមកនូវឯកសារផ្សេងៗដែលពាក់ព័ន្ធក្នុងរឿងខាងលើ មកជាមួយផង ប្រសិនបើមាន ។

ថ្ងៃចន្ទ ១៤រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២០
**តំណាងអយ្យការ**

[redacted]
**ព្រះរាជអាជ្ញារង**

យើង.................................ជា..............................
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ:...............................
ទីលំនៅបច្ចុប្បន្នផ្ទះ: ៣/០ ផ្លូវលេខ..........សង្កាត់..............
ខណ្ឌ.................រាជធានីភ្នំពេញ នៅថ្ងៃទី..........ខែ..............
ឆ្នាំ..............រួចរាល់ហើយ ដោយយើងបានទុកចុងដីកាកោះនេះមួយច្បាប់អោយសាមីខ្លួនហើយប្រាប់ថាអោយសាមីខ្លួនប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់អយ្យការ។

**អ្នកទទួល** **អ្នកប្រគល់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

# ដីកាកោះឱ្យចូលខ្លួន

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៥៣៦ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៩។

-បានឃើញ សាលដីកាបញ្ជូនរឿងទៅជំនុំជម្រះ... លេខ ៥៩៣៨ "ម" ង.ដ ចុះថ្ងៃទី០ ៧ ខែ កញ្ញា ឆ្នាំ២០២០ របស់

-បានឃើញ ដីកាដំណោះស្រាយលេខ ... របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានផ្តើមចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ៧០ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ ឈ្មោះ [redacted] ភេទស្រី អាយុ ៦៥ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៧១ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥០ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ឆ្នាំ ឈ្មោះ [redacted] ភេទស្រី អាយុ៦៩ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ៧២ឆ្នាំ ពីបទ **ឧបឃាត** ប្រព្រឹត្តនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ២៧ និង មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ។

## ក្រោយពីបានដាក់រឿងជំនុំជម្រះរួចមកសម្រេច៖

បង្គាប់មកឈ្មោះ [redacted] ភេទប្រុស អាយុ៧០ឆ្នាំ ជាតិខ្មែរ មុខរបរៈអតីតប្រធានគណបក្សសង្គ្រោះជាតិ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៥៧៦ ព្រែកតាគង់២ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី**១១** ខែ**វិច្ឆិកា** ឆ្នាំ**២០២០** វេលាម៉ោង**០៨:០០**នាទីព្រឹក (សាលសវនាការទី១ ជាន់ទី១) ជាកំហិត ដើម្បីឆ្លើយដោះសារពីការចោទប្រកាន់នេះ។

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ
-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ
-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

អំពីសិទ្ធិរបស់ជនជាប់ចោទ៖

១-សិទ្ធិទទួលដឹងអំពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលខ្លួន
២-សិទ្ធិបង្ហាញភស្តុតាង សំអាងហេតុ សាក្សី និងសំណូមពរផ្សេងៗ
៣-សិទ្ធិប្តឹងឧបសគ្គទៅក្រុមជំនុំជម្រះ
៤-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសុំមេធាវីជួយការពារ ឬអ្នកឯទៀតណាមួយផ្សេងទៀត។
៥-សិទ្ធិនិយាយសម្តីចុងក្រោយ។

ថ្ងៃ ចន្ទ ៣កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០២០
តំណាងអយ្យការ

[redacted]
ព្រះរាជអាជ្ញារង

អាសយដ្ឋាន៖ អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧ | ២១៣ សង្កាត់វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ
Address : # 25-27 Street 217 | 213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia
ទូរសារ-ទូរស័ព្ទ៖ (៨៥៥ - ២៣ ៨៨ ២០ ៥៩
Fax- Phone : (855) - 23 88 20 59

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥៧៨
ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៨

# ដីកាកោះ

**យើង [redacted] តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ [redacted] ជា ជនសង្ស័យ

ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ ភូមិព្រែកតាគង់២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អោយចូលទៅកាន់ **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** បន្ទប់ (ឋ) ជាន់ទី២

នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨ វេលាម៉ោង ០៩:០០ នាទី ព្រឹក

ដើម្បី បំភ្លឺដំណើររឿង ពីការចុះកិច្ចព្រមព្រៀងជាមួយឈ្មោះ កុក ស នៅថ្ងៃទី១៩.៤.២០១៣ ពាក់ព័ន្ធនិងការកាត់ទឹកដី ០៤ខេត្ត ឲ្យជនជាតិដើមភាគតិច ដេហ្គា (ម៉ុងតាញ៉ា) គ្រប់គ្រង ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកានេះ ឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃ ព្រហស្បតិ៍ ០៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ពស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៨

ជ. ព្រះរាជអាជ្ញា

[redacted]

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

2839

5.11.20 4

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

# ដីកាកោះឱ្យចូលសវនាការ

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា ២៦៤ និងមាត្រាដែលពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៧២៥ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ សំណុំរឿងជំនុំជម្រះលេខ ៥៧៨១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៦៤៦០ "ម" ដ.ង ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់លើឈ្មោះ [redacted] ពីបទ "រួមគំនិតក្បត់ និងបទញុះញង់ឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" ប្រព្រឹត្តនៅប្រទេសកម្ពុជា កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥៣, មាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

<u>ក្រោយពីបានដាក់រឿងជំនុំជម្រះរួច សម្រេច៖</u>

បង្គាប់ឱ្យឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ

ទីកន្លែងកំណើត៖ ភូមិស្រះកែវ ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង

អាសយដ្ឋាន៖ ផ្ទះលេខ៦៤១ ក្រុមទី១៥ ភូមិស្រះកែវ ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ (ជាន់ទី១ សាលសវនាការទី១) <u>នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង០៨ និង៣០នាទីពេលព្រឹក</u> ជាកំហិត ដើម្បីចូលរួមសវនាការ ។

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

អាស័យដ្ឋាន : អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧ ⊥ ២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ
Address : # 25-27, Street 217⊥ 213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ : (៨៥៥ - ២៣ ៨៨ ២០ ៥៩
Fax- Phone : (855) - 23 88 20 59

[illegible]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**



សាលាដំបូងរាជធានីភ្នំពេញ

លេខ 224 ច.ក្រម

## ដីកាបង្គាប់ឲ្យចូលខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៧៥២២ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៨

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣១៤៦ អ.យ.ជ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩ ចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ។

ពីបទៈ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅ ភូមិខ្លា និងភូមិបឹងខ្លា ឃុំទួលព្រេច ស្រុកសង្កស្អូល ខេត្តកណ្ដាល កាលពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-បង្គាប់ឲ្យឈ្មោះ [redacted] ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ៣៨ ផ្លូវលេខ ៧ បុរីពិភពថ្មី (បឹងឈូក) ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ "ច" ជាន់ទី៣ ថ្ងៃទី...២១.....ខែ.មេសា ឆ្នាំ ២០២០ វេលាម៉ោង.....8:30 ព្រឹក.ដើម្បី សាកសួរ ពីដំណើររឿង រំលោភលើទំនុកចិត្ត ។

សាមីខ្លួនត្រូវយកលិខិតផ្សេងៗ ដែលទាក់ទងរឿងខាងលើទៅជាមួយផងប្រសិនបើមាន ករណីមិនចូលតាមកាលកំណត់ខាងលើនោះទេ យើងនឹងចេញដីកាបង្គាប់ឲ្យនាំខ្លួន ។

ថ្ងៃ.[illegible]..ខែចេត្រ ឆ្នាំកុរ [illegible] ស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី..២១..ខែ [illegible] ឆ្នាំ ២០២០

**ចៅក្រមស៊ើបសួរ**

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះឱ្យចូលខ្លួន

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៥៣៦ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៩។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥៩៣៨ "ម"ដ.ង ចុះថ្ងៃទី០ ៧ ខែ កញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានផ្ដើមចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ៧០ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ ឈ្មោះ [redacted] ភេទស្រី អាយុ ៦៥ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥០ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៧១ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៤៩ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ ឆ្នាំ ឈ្មោះ [redacted] ភេទស្រី អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ៧២ឆ្នាំ ពីបទ **ឧបឃាត** ប្រព្រឹត្តនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ២៧ និង មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ។

## ក្រោយពីបានដាក់រឿងជំនុំជម្រះរួចមកសម្រេច៖

បង្គាប់មកឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ រស់នៅបច្ចុប្បន្នផ្ទះលេខ៖១៦៨ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង០៨:០០នាទីព្រឹក (សាលសវនាការទី១ ជាន់ទី១) ជាកំហិត ដើម្បីឆ្លើយដោះសារពីការចោទប្រកាន់នេះ។

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

អំពីសិទ្ធិរបស់ជនជាប់ចោទ៖

១-សិទ្ធិទទួលនិងអំពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលខ្លួន
២-សិទ្ធិបង្ហាញភស្តុតាង សំអាងហេតុ សាក្សី និងសំណូមពរផ្សេងៗ
៣-សិទ្ធិថ្លែងបដិសេធទៅក្រុមជំនុំជម្រះ
៤-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសុំមេធាវីជួយការពារ ឬអ្នកដទៃណាមួយផ្សេងទៀត។
៥-សិទ្ធិនិយាយសម្ដីចុងក្រោយ។

ថ្ងៃ ចន្ទ ៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០២០
តំណាងអយ្យការ

[redacted]
ព្រះរាជអាជ្ញារង

អាស័យដ្ឋាន : អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧ ⊥ ២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា. ភ្នំពេញ
Address : # 25-27, Street 217⊥ 213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ : (៨៥៥ - ២៣ ៨៨ ២០ ៥៩
Fax- Phone : (855) - 23 88 20 59

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាកោះឱ្យចូលខ្លួន

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៥៣៦ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៩។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥៩៣៨ "ម" ង.ឆ ចុះថ្ងៃទី០ ៧ ខែ កញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានផ្ដើមចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ៧០ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ ឈ្មោះ [redacted] ភេទស្រី អាយុ ៦៥ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥០ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៧១ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ ឆ្នាំ ឈ្មោះ [redacted] ភេទស្រី អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ៧២ឆ្នាំ ពីបទ **ឧបឃាត** ប្រព្រឹត្តនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ២៧ និង មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ។

**ក្រោយពីបានដាក់រឿងជំនុំជម្រះរួចមកសម្រេច៖**

បង្គាប់មកឈ្មោះ [redacted] ភេទប្រុស អាយុ៧១ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៩A ផ្លូវ៥៥៤ ភូមិ៧ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ **នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង០៨:០០នាទីព្រឹក (សាលសវនាការទី១ ជាន់ទី១)** ជាកំហិត ដើម្បីឆ្លើយដោះសារពីការចោទប្រកាន់នេះ។

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ
-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ
-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

អំពីសិទ្ធិរបស់ជនជាប់ចោទ៖

ក-សិទ្ធិទទួលដឹងអំពីសិទ្ធិគេចោទប្រកាន់ទោស និងដីកាកោះឱ្យចូលខ្លួន
ខ-សិទ្ធិបង្ហាញភស្តុតាង សំអាងហេតុ សាក្សី និងសំណូមពរផ្សេងៗ
គ-សិទ្ធិថ្លែងបំភ្លឺទៅក្រុមជំនុំជម្រះ
ឃ-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសុំមេធាវីជួយការពារ ឬអ្នកណាម្នាក់ផ្សេងទៀត។
ង-សិទ្ធិនិយាយសម្ដីចុងក្រោយ។

ថ្ងៃ ចន្ទ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២០
**តំណាងអយ្យការ**

[redacted]

អាសយដ្ឋាន : អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧ ⊥ ២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា. ភ្នំពេញ
Address : # 25-27, Street 217⊥213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ : (៨៥៥ - ២៣ ៨៨ ២០ ៥៩
Fax- Phone : (855) - 23 88 20 59

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកោះកុង**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០៤

ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១

# ដីកាកោះ

យើង [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង

អញ្ជើញលោក : [redacted] មុខរបរជាអ្នកសារព័ត៌មាន ជា ជនសង្ស័យ

ទីលំនៅបច្ចុប្បន្នៈ នៅភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

ឱ្យចូលមកកាន់ : អយ្យការអមសាលាដំបូងខេត្តកោះកុង នៅជាន់ទី០១ បន្ទប់លេខ ១៤ "គ" នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០២ : ៣០នាទីរសៀល

ដើម្បី : បំភ្លឺ

ពីដំណើររឿង : តាមពាក្យបណ្តឹងរបស់លោក ម៉ា ទី ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះ ឱ្យបានទាន់ពេលវេលាកុំបីខាន និងយកលិខិត ឬឯកសារផ្សេងៗ ដែលទាក់ទងក្នុងរឿងខាងលើមកជាមួយផង មកជាមួយផង។

ថ្ងៃពុធ ៨រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

អយ្យការអមកោះកុង, ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១

**តំណាងអយ្យការ**

[redacted]

**ព្រះរាជអាជ្ញារង**

យើង[redacted] ជា[illegible] បានប្រគល់ដីកាកោះនេះ ឱ្យទៅឈ្មោះ[redacted] ភេទ ប្រុស អាយុ 60 ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ[illegible] សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង នៅថ្ងៃទី 14 ខែមករា ឆ្នាំ២០២១ ហើយប្រាប់ថាឱ្យប្រគល់ចុងដីកាកោះនេះ ដល់លោក អិន ស៊ីងទ្រី ជាក្រឡាបញ្ជី នៅពេលខ្លួនទៅដល់អយ្យការអមសាលាដំបូងកោះកុង នៅជាន់ទី០១ បន្ទប់លេខៈ ០៩ "ក"[2]។

អ្នកទទួលលិខិត

[redacted]

អ្នកប្រគល់

[redacted]

[2]កំណត់សម្គាល់: អ្នកប្រគល់ដីកានេះ ក្រោយពីអ្នកទទួលដីកា បានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ លើដីកានោះ ទាំងពីរសន្លឹករួចហើយ ត្រូវប្រគល់ដីកា(ចុងដីកា) ទៅឱ្យអ្នកទទួល និងបង្វិលដីកា (ដើមដីកា) ទៅតុលាការវិញឱ្យបានមុនថ្ងៃកំណត់របស់តុលាការ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូទី៣
បទប.៥.

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ៦៥៤១
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

# ដីកាកោះ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ជាដើមបណ្តឹង។

-អាសយដ្ឋាន បន្ទប់ជួលផ្ទះលេខ៩៣អឺ៣ ផ្លូវលេខ១៥២ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។
ប្រើទូរស័ព្ទលេខ ០៨៦ ៩៥០ ៩៣៨

-អោយចូលទៅកាន់ **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-នៅថ្ងៃ ព្រហស្បតិ៍ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង០៨និង០០នាទី។

-ដើម្បី សាកសួរបំភ្លឺ។

-ពីដំណើររឿង តាមពាក្យបណ្តឹង ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ របស់ខ្លួន ប្តឹង លើឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ **ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស។**

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះ នេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ សុក្រ ៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០
**តំណាងអយ្យការ**

[redacted]
ព្រះរាជអាជ្ញារង

យើង..............................
បានប្រគល់ដីកាកោះនេះមួយច្បាប់ឲ្យទៅ
ឈ្មោះ ..............................
នៅថ្ងៃទី..............ខែ..............ឆ្នាំ២០២០

**អ្នកទទួល** **អ្នកប្រគល់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកំពង់ឆ្នាំង
*សំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៨*
*ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤*

## ដីកាកោះឱ្យចូលខ្លួន

**យើង** [redacted] **តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ឆ្នាំង**

បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖ ៦១០/១៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

ចោទប្រកាន់លើ៖

១/.ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៤ឆ្នាំ, ២/.ឈ្មោះ [redacted] ភេទប្រុស អាយុ ៤១ឆ្នាំ, ៣/.ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៤ឆ្នាំ, ៤/.ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៩ឆ្នាំ, ៥/.ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ, ៦/.ឈ្មោះ [redacted] ភេទប្រុស អាយុ ៦៧ឆ្នាំ និង៧/.ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំ

ពីបទ៖ ហិង្សាដោយចេតនា និងធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

**ក្រោយពីជាក់រឿងជំនុំជម្រះ**

**សំរេច**

បង្គាប់ឱ្យឈ្មោះ [redacted] ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចូលខ្លួនមកកាន់ សាលសវនាការនៃសាលាដំបូងខេត្តកំពង់ឆ្នាំង នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០៨ព្រឹក ជាកំហិត ដើម្បី ឆ្លើយបំភ្លឺក្នុងសវនាការ ពីបទដូចមានចែងខាងលើ។ (សាលសវនាការទី១)

**សមាសភាពជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមជំនុំជម្រះ
-លោក [redacted] ជាតំណាងអយ្យការ
-លោក [redacted] ជាក្រឡាបញ្ជីសវនាការ

**សិទ្ធិរបស់ជនជាប់ចោទ:**

*-សិទ្ធិទទួលដឹងឮពីដីកាសន្និដ្ឋានស្ថាពរ ឬដីកាសន្និដ្ឋានចោទប្រកាន់ ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬបន្ទាន់ និង ដីកាកោះឱ្យចូលខ្លួន ។*
*-សិទ្ធិបង្ហាញភស្តុតាង សំអាង សាក្សី ឬធ្វើសំណូមពរផ្សេងៗ*
*-សិទ្ធិប្តឹងបដិសេធចៅក្រមជំនុំជម្រះ ។*
*-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសុំឱ្យមានមេធាវីជួយការពារ ឬតែង អ្នកដទៃណាមួយឱ្យជួយការពារខ្លួន ។*
*-សិទ្ធិនិយាយសំដីចុងក្រោយ ។*

ថ្ងៃសុក្រ ០១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅកំពង់ឆ្នាំង, ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១
**ព្រះរាជអាជ្ញារង**

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកំពង់ឆ្នាំង
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៨
ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១

# ដីកាកោះ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

អញ្ជើញឈ្មោះ [redacted] ភេទប្រុស ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ឲ្យចូលមកកាន់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង(បន្ទប់លេខ៣)

នៅថ្ងៃទី.......ខែ..........ឆ្នាំ ២០២១ វេលាម៉ោង..........នាទី

ដើម្បី សាកសួរ

ពីដំណើររឿង ប៉ុនប៉ងឃាតកម្ម និងធ្វើឲ្យខូចខាតដោយចេតនា ដែលឈ្មោះ ប៉ក់ សុខន ប្ដឹងមកលើឈ្មោះ សួន ញៀន ឈ្មោះ អុំ សុភី ឈ្មោះ អ៊ិន ម៉ុន និងខ្លួន ។

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ ឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយ ប្រសិនបើមាន។

ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កំពង់ឆ្នាំង ថ្ងៃទី.......ខែ.........ឆ្នាំ ២០២១

**ព្រះរាជអាជ្ញារង**

[redacted]

យើង.......... [redacted] ..........................................

បានប្រគល់ដីកាកោះនេះឲ្យឈ្មោះ [redacted] .......... [redacted] ..........

នៅ........................ផ្លូវ.............ភូមិ..............ឃុំ.សង្កាត់..............ស្រុក.ខណ្ឌ..............

ខេត្ត.រាជធានី..............នៅថ្ងៃទី..21.....ខែ..04.....ឆ្នាំ.2021......... ដោយផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះ មួយច្បាប់ឲ្យសាមីខ្លួន ហើយប្រាប់ឲ្យសាមីខ្លួន ប្រគល់ចុងដីកានេះ ដល់ក្រឡាបញ្ជីនៅពេលចូលខ្លួនដល់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**អ្នកទទួល** | **អ្នកប្រគល់**

ហត្ថលេខា ឬស្នាមម្រាមដៃ

[redacted]

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង...រាជធានីភ្នំពេញ
សំណុំរឿង......ព្រហ្មទណ្ឌ........
លេខ ...៣២៤១/១១-០៧-២០១៦

[redacted]

## ដីកាកោះ

លើកទី២

យើង [redacted] ចៅក្រមស៊ើបសួរ ............ សាលាដំបូងខេត្ត-រាជធានី ...ភ្នំពេញ......

................................................................................

អញ្ជើញឈ្មោះ [redacted] ...ជា ......... ដើមបណ្តឹងរដ្ឋប្បវេណី.........

ទីលំនៅសព្វថ្ងៃ .......ផ្ទះលេខ៨BE ........ ផ្លូវលេខ៣៩២ សង្កាត់បឹងកេងកងទី១ ........ ខណ្ឌចំការមន......

រាជធានីភ្នំពេញ..................................................................

អោយចូលទៅកាន់ .......សាលាដំបូងរាជធានីភ្នំពេញ (បន្ទប់ "ផ" ជាន់ទី៤).......................

នៅថ្ងៃទី ...១៧......ខែ ...តុលា...ឆ្នាំ........២០១៦....វេលាម៉ោង .........១៤:៣០ នាទី.................

ដើម្បី .......មកចូលរួមសាកសួរ.................................................

ពីដំណើរ ...រឿង ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិ១៣ សង្កាត់

ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦។...........

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែល ទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅ .......រាជធានីភ្នំពេញ...ថ្ងៃទី ...២៦.....ខែកញ្ញា.....ឆ្នាំ ២០១៦..

ចៅក្រមស៊ើបសួរ

[redacted]